ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២១ លេខ ១ ខែមីនា ២០១៧ តម្លៃ ១.៥០០៛

# តើថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជា បានកំណត់ និងមានចំណាប់អារម្មណ៍យ៉ាងណាលើ អន្តរជាតូបនីយកម្មឧត្តមសិក្សា

## សេចក្តីផ្តើម

សាកលភាវូបនីយកម្ម និងការអភិវឌ្ឍក្នុងតំបន់យ៉ាងខ្លាំងក្លា ដែលកើតមានឡើងតាំងពីដើមទសវត្សរ៍១៩៩០ បាននាំឲ្យមានកំណើនគួរឲ្យកត់សម្គាល់នូវ សកម្មភាពអន្តរជាតិក្នុងអនុវិស័យឧត្តមសិក្សាទូទាំងសកលលោក។ ពីឆ្នាំ២០០០ ដល់ ២០១៣ ចំនួននិស្សិតចេញទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅបរទេស បានកើនមួយជាពីររហូតដល់ ៤,១លាននាក់ ត្រូវជា ១,៨% នៃចំនួននិស្សិតសរុប ដែលរៀនថ្នាក់ឧត្តមសិក្សាក្នុងទូទាំងពិភពលោក (UIS2016)។ សហរដ្ឋអាមេរិកជាប្រទេសគោលដៅទាក់ទាញខ្លាំងជាងគេ ដោយបានស្រូបយកនិស្សិតអន្តរជាតិចល័តជាង ១៩% ក្នុងឆ្នាំ២០១៣ បន្ទាប់មកគឺ អង់គ្លេស (១០%) អូស្ត្រាលី (៦%) បារាំង (៦%) និងអាឡឺម៉ង់ (៥%)។ នៅឆ្នាំ២០១៦ ប្រទេសបួនដែលមាននិស្សិតចេញទៅរៀននៅបរទេសច្រើនជាងគេគឺ ចិន (៨០១.១៨៧នាក់) ឥណ្ឌា (២៥៥.០៣០នាក់) អាឡឺម៉ង់ (១១៦.៣៤២នាក់) និងកូរ៉េខាងត្បូង (១០៨.០៤៧នាក់) (UIS 2017)។ សកម្មភាពផ្សេងទៀតក៏មានកំណើនគួរឲ្យកត់សម្គាល់ដែរ ដូចជា ការបង្កើតសាខាគ្រឹះស្ថានឧត្តមសិក្សាបរទេស កិច្ចសហការស្រាវជ្រាវ និងកម្មវិធីសិក្សាសញ្ញាបត្ររួម។ នៅកម្រិតគោលនយោបាយវិញ អន្តរជាតូបនីយកម្ម បានវិវត្តពីលក្ខណៈតូចតាចទៅជាចំណុចស្នូលមួយនៃ គោលនយោបាយថ្នាក់ជាតិ និងថ្នាក់ស្ថាប័នក្នុងប្រទេសជាច្រើន។



*សកម្មភាពអន្តរជាតូបនីយកម្មក្នុងឧត្តមសិក្សា បានកើនឡើងនៅក្នុងប្រទេសកម្ពុជា*
*វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ខែកុម្ភៈ ២០១៧។*

នៅកម្ពុជា សកម្មភាពអន្តរជាតូបនីយកម្មក្នុងឧត្តមសិក្សាបានកើនឡើង តាំងពីប្រទេសនេះ បានចាប់ផ្តើមចូលសហគមន៍នៅក្នុងតំបន់ និងអន្តរជាតិ នៅដើមទសវត្សរ៍១៩៩០។ សកម្មភាពទាំងនេះ រួមមាន ភាពចល័តរបស់និស្សិតនិងសាស្ត្រាចារ្យ ការស្រាវជ្រាវរួមគ្នា និងភាពជាដៃគូអន្តរជាតិ។ ចំនួននិស្សិតចេញទៅរៀនថ្នាក់ឧត្តមសិក្សា នៅបរទេសក្នុងឆ្នាំ២០១៦ មានចំនួន

## មាតិកា

តើថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជាបានកំណត់ និងមានចំណាប់អារម្មណ៍យ៉ាងណាលើ អន្តរជាតូបនីយកម្មឧត្តមសិក្សា.................................... ១

ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្រដល់សហគមន៍អេកូទេសចរណ៍នៅកម្ពុជា៖ វិធីសាស្ត្រ ម៉ូដែលសមីការជាប្រព័ន្ធ................................ ៨

តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ...................... ១៤

— ស្ថានភាពក្នុងប្រទេស...................... ១៦

ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......................................២៤

---

តឹក ម៉ុយទៀង ជាជំនួយការស្រាវជ្រាវ និង បណ្ឌិត ឡេង ភីរម្យ ជាអ្នកស្រាវជ្រាវនៅផ្នែកអប់រំ នៅវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា: Tek Muy Tieng and Leng Phirom. 2017. “How do Cambodian Academic Leaders Define and Perceive Higher Education Internationalisation?” *Cambodia Development Review* 21(1): 1-7.

ក្រុមអ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី ចំពោះជំនួយគាំទ្រហិរញ្ញវត្ថុដ៏សប្បុរសដល់ការស្រាវជ្រាវនេះ។

៥.២៧៥នាក់ ស្មើនឹង ២,៤% (UIS 2017)។ ដូចមានចុះនៅក្នុង តារាង១ ប្រទេសគោលដៅចម្បងៗ (គិតតាមលំដាប់សារៈសំខាន់) របស់និស្សិតកម្ពុជា គឺ ថៃ អូស្ត្រាលី បារាំង សហរដ្ឋអាមេរិក និង វៀតណាម។ អ្នកផ្ដល់សេវាអប់រំបរទេសជាច្រើនដែលមានទីតាំងនៅកម្ពុជា រួមមាន សាកលវិទ្យាល័យលីមកុកវីងរបស់ម៉ាឡេស៊ី សាលារៀនអន្តរជាតិរាហ្វល របស់អូស្ត្រាលី ព្រមទាំងការិយាល័យប្រចាំនៅកម្ពុជានៃ សាកលវិទ្យាល័យជប៉ុនពីរ គឺ ណាហ្គូយ៉ា និង ហ៊ីរ៉ូស៊ីម៉ា ដែលផ្ដល់កម្មវិធីសិក្សាថ្នាក់ក្រោយឧត្ដមសិក្សាផ្នែកអភិវឌ្ឍន៍ (សាកលវិទ្យាល័យណាហ្គូយ៉ា) និងផ្នែកអប់រំ (សាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា)។

តារាង១៖ ប្រទេសគោលដៅចម្បងៗប្រាំរបស់និស្សិតកម្ពុជាក្នុងឆ្នាំ២០១៦

| ប្រទេសគោលដៅ | ចំនួននិស្សិត |
|---|---|
| ថៃ | 1182 |
| អូស្ត្រាលី | 784 |
| បារាំង | 611 |
| សហរដ្ឋអាមេរិក | 527 |
| វៀតណាម | 381 |

ប្រភព៖ UNESCO Institute of Statistics (2017)

ទោះបីមានកំណើនសកម្មភាពយ៉ាងនេះក្ដី ឯកសារស្រាវជ្រាវអំពីអន្តរជាតូបនីយកម្មឧត្ដមសិក្សានៅកម្ពុជា នៅមានតិចតួចនៅឡើយនាបច្ចុប្បន្ន ហើយសាធារណជន ក៏មានការយល់ឃើញខុសៗគ្នាពីផ្នែកនេះដែរ។ ការសិក្សាពីឧត្ដមសិក្សានៅកម្ពុជាក្នុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ ផ្ដោតជាសំខាន់លើកម្លាំងអំណាច ជាពិសេស ឥទ្ធិពលរបស់រដ្ឋាភិបាល និងទីភ្នាក់ងារបរទេស ទៅលើគ្រឹះស្ថានឧត្ដមសិក្សាក្នុងស្រុក តាមរយៈជំនួយផ្នែកអប់រំរបស់ពួកគេ (Pit and Ford 2004; Clayton 2006)។ ដូច្នេះហើយ ការសិក្សានេះ មានគោលដៅស្វែងយល់ពីការដាក់និយមន័យ និងការយល់ឃើញរបស់ ថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជា អំពីពាក្យ "អន្តរជាតូបនីយកម្មឧត្ដមសិក្សា" ក្នុងស្ថានភាពដែលប្រទេសកម្ពុជា កាន់តែមានការចូលរួមច្រើនឡើងនៅក្នុងតំបន់ និងអន្តរជាតិ។ ជាបន្ត ឯកសារនេះ នឹងបង្ហាញពីក្របខ័ណ្ឌគោលគំនិតនៃការសិក្សា បន្ទាប់មក វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលរកឃើញនិងការពិភាក្សា និងការផ្ដល់ជាមតិមួយចំនួននៅចុងបញ្ចប់។

## ក្របខ័ណ្ឌគោលគំនិត

ផ្នែកនេះ ផ្ដល់នូវក្របខ័ណ្ឌគោលគំនិតសម្រាប់ការស្រាវជ្រាវ ដោយដំបូងអ្នកស្រាវជ្រាវ ពិនិត្យពីនិយមន័យ បន្ទាប់មកពីចំណាប់អារម្មណ៍ខុសៗគ្នាលើអន្តរជាតូបនីយកម្ម។ អន្តរជាតូបនីយកម្មនៃឧត្ដមសិក្សា ចាប់ផ្ដើមមានការពេញនិយមយ៉ាងខ្លាំងក្នុងពីរទសវត្សរ៍កន្លងមក ប៉ុន្តែពាក្យផ្សេងៗទៀត ដូចជា សហប្រតិបត្តិការអន្តរជាតិ ការអប់រំអន្តរជាតិ ទំនាក់ទំនងអន្តរជាតិ មានយកមកប្រើតាំងពីទសវត្សរ៍ ១៩៦០ ម្ល៉េះ។ ដើមឡើយ ពាក្យ "អន្តរជាតូបនីយកម្ម" សំដៅដល់ សកម្មភាពមួយឈុតដែលទាក់ទងនឹងការសិក្សាឬកម្មវិធីសិក្សាអន្តរជាតិ និងការអប់រំផ្នែកភាសា (Knight 2008)។ ចាប់ពីពេលនោះមក ពាក្យនេះ បានវិវត្តក្នុងបរិបទមានការផ្លាស់ប្ដូរជាច្រើនក្នុង ឧត្ដមសិក្សានៅទូទាំងសាកលលោក ហើយវាក៏ត្រូវបានដាក់និយមន័យ និងយល់ឃើញខុសៗគ្នា ពីសំណាក់អ្នកពាក់ព័ន្ធមកពីវិស័យផ្សេងៗគ្នា។ និយមន័យដែលគេលើកឡើងជាញឹកញាប់ គឺរបស់ Knight (2008, 21) ដែលពិពណ៌នាពីអន្តរជាតូបនីយកម្មឧត្ដមសិក្សាថាជា "ដំណើរការនៃការដាក់បញ្ចូលធាតុ អន្តរជាតិ អន្តរវប្បធម៌ ឬសកល ទៅក្នុង គោលដៅ មុខងារ ឬការផ្ដល់សេវាអប់រំថ្នាក់ឧត្ដមសិក្សា"។ និយមន័យនេះ មានលក្ខណៈពិសេសព្រោះវាមានន័យអព្យាក្រឹត ដោយផ្ដល់គំនិតថា ដំណើរការនេះ អាចមានភាពវិជ្ជមាន ឬអវិជ្ជមាន ឬក៏អាចមានទាំងពីរមុខ ទៅតាមបែបបទដែលគេពិនិត្យមើលវា។

ការសិក្សាមួយនៅឆ្នាំ២០១៥ ធ្វើឡើងដោយ សភាអឺរ៉ុប បានរកឃើញថា សាកលវិទ្យាល័យនានាគួរយកចិត្តទុកដាក់ទៅលើគុណភាពកម្មវិធីសិក្សារបស់ខ្លួន និងលទ្ធផលរៀនសូត្ររបស់និស្សិត (បញ្ហាក្នុងស្រុក) ជាជាងផ្ដោតតែទៅលើសកម្មភាពនៅក្រៅប្រទេស។ ដោយពង្រីកនិយមន័យគោលរបស់ Knight សភាអឺរ៉ុបបានឲ្យនិយមន័យអន្តរជាតូបនីយកម្មថាជា"ដំណើរការដោយចេតនានៃការដាក់បញ្ចូល ធាតុ អន្តរជាតិ អន្តរវប្បធម៌ ឬសកល ទៅក្នុងគោលដៅ មុខងារ ឬការផ្ដល់សេវាអប់រំថ្នាក់ឧត្ដមសិក្សា ដើម្បីលើកស្ទួយគុណភាពនៃការអប់រំ និងស្រាវជ្រាវ សម្រាប់និស្សិត និងបុគ្គលិកទាំងអស់ និងដើម្បីចូលរួមដោយមានន័យក្នុងការអភិវឌ្ឍសង្គម" (de Wit et al. 2015)។ និយមន័យនេះ មានការរាប់បញ្ចូលមនុស្សគ្រប់គ្នា និងផ្អែកលើគំនិតចង់ឲ្យមានសមធម៌ក្នុងសង្គម ដោយកំណត់ឲ្យអន្តរជាតូបនីយកម្មមានលក្ខណៈសម្រាប់គ្រប់គ្នា ជាជាង សម្រាប់តែនិស្សិតនិងក្រុមសាស្ត្រាចារ្យមួយចំនួនតូចដែលបានចេញទៅបរទេស។

មតិទិតៀនមួយទៀតដល់និយមន័យរបស់ Knight កើតចេញពី Hawawini (2016) ដែលបានរកឃើញនៅក្នុងការសិក្សារបស់គាត់ស្ដីពី អន្តរជាតូបនីយកម្មនៃគ្រឹះស្ថានឧត្ដមសិក្សា និងសាលាពាណិជ្ជកម្មថា អន្តរជាតូបនីយកម្ម មិនគួរកំណត់ព្រំដែនឲ្យតូចចង្អៀត ត្រឹមតែ ដំណើរការដាក់បញ្ចូលធាតុអន្តរជាតិទៅក្នុងរចនាសម្ព័ន្ធស្ថាប័ន និងលំនាំមានស្រាប់ (ដំណើរការឯកទិស ជាជាង ដំណើរការទ្វេទិស) នោះទេ។ ដូច្នេះហើយ គាត់បានស្នើឡើងនូវនិយមន័យថ្មីមួយនៃ អន្តរជាតូបនីយកម្មឧត្ដមសិក្សាថាជា "ដំណើរការកំពុងទៅមុខនៃការផ្លាស់ប្ដូរដែលមានគោលដៅដាក់បញ្ចូលស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ (និស្សិត និងសាស្ត្រាចារ្យ) ទៅក្នុងសេដ្ឋកិច្ចសកលផ្អែកលើចំណេះដឹងដែលកំពុងផុសឡើង" (Hawawini 2016, 5)។ ស្រដៀងគ្នាដែរ ប៉ុន្តែផ្អែកលើគំនិតវិភាគតាមលក្ខណៈទីតាំង Larsen (2016, 10) បានកំណត់និយមន័យអន្តរជាតូបនីយកម្មឧត្ដមសិក្សាថាជា "ការពង្រីកវិសាលភាពសាកលវិទ្យាល័យ ឲ្យហួសពីព្រំដែនប្រទេស តាមរយៈភាពចល័តនៃនិស្សិត អ្នកស្រាវជ្រាវ ចំណេះដឹង

តារាង២៖ ហេតុផលបួននៃការធ្វើអន្តរជាតូបនីយកម្មគ្រឹះស្ថានឧត្តមសិក្សា

| | |
|---|---|
| សង្គម/វប្បធម៌ | អត្តសញ្ញាណវប្បធម៌ជាតិ<br>ការយោគយល់អន្តរវប្បធម៌<br>ការអភិវឌ្ឍភាពជាពលរដ្ឋ<br>ការអភិវឌ្ឍសង្គម និងសហគមន៍ |
| នយោបាយ | គោលនយោបាយការបរទេស<br>សន្តិសុខជាតិ<br>ជំនួយបច្ចេកទេស<br>សន្តិភាព និងការយោគយល់គ្នា<br>អត្តសញ្ញាណជាតិ<br>អត្តញ្ញាណក្នុងតំបន់ |
| សេដ្ឋកិច្ច | កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែង<br>ទីផ្សារពលកម្ម<br>គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ |
| សិក្សាស្រាវជ្រាវ | ការពង្រីកព្រំដែននៃការសិក្សា<br>ការកសាងស្ថាប័ន<br>កេរ្តិ៍ឈ្មោះ និងឋានៈ<br>ការលើកកម្ពស់គុណភាព<br>ស្តង់ដាសិក្សាអន្តរជាតិ<br>ការបញ្ចូលធាតុអន្តរជាតិទៅក្នុងការស្រាវជ្រាវ និងបង្រៀន |

ប្រភព៖ Knight (2004)

កម្មវិធីសិក្សា និងអ្នកផ្តល់សេវាអប់រំ"។ ថ្វីបើមានភាពល្អៀងន័យគ្នាខ្លះ ការសិក្សានេះ បានវែកញែកថា អំណះអំណាងទាំងនោះ គឺមានភាពដូចគ្នាជាច្រើនជាមួយនឹង លក្ខណៈស្នូលនៃនិយមន័យរបស់ Knight (2008) ដែលគ្របដណ្តប់លើធាតុជាច្រើន ទាំង "នៅក្នុងស្រុក" និង "នៅក្រៅស្រុក"។ ដូច្នេះ ឯកសារស្រាវជ្រាវនេះបានយកនិយមន័យរបស់ Knight មកប្រើជាក្របខ័ណ្ឌសម្រាប់ពិនិត្យពីបែបបទដែល អ្នកដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជាកំណត់និយមន័យឲ្យពាក្យ "អន្តរជាតូបនីយកម្មឧត្តមសិក្សា"។

សព្វថ្ងៃនេះ មានមតិចម្រុះគ្នាជាច្រើនអំពី ដំណើរការអន្តរជាតូបនីយកម្ម។ ម្យ៉ាង មានមនុស្សជាច្រើនមើលឃើញអន្តរជាតូបនីយកម្ម ថាជា ឱកាសក្នុងការផ្តល់ការអប់រំឲ្យបានស្មើភាពគ្នាដល់ អ្នកដែលកំពុងស្វែងរក ឱកាសរៀនសូត្រ។ គំនិតវិជ្ជមាននេះ ជាទូទៅផុសចេញពី ហេតុផលបួនដែលគាំទ្រឲ្យមានអន្តរជាតូបនីយកម្មឧត្តមសិក្សា ពោលគឺ ហេតុផលផ្នែកសង្គម/វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងសិក្សាស្រាវជ្រាវ (Knight 2004; de Wit 2002) ដូចមានចុះក្នុង តារាង២។ ហេតុផលទាំងនេះ មិនមានលក្ខណៈដាច់ពីគ្នានោះទេ ប៉ុន្តែសារៈសំខាន់របស់ហេតុផលនីមួយៗ អាចប្រែប្រួលទៅតាមពេលវេលា និងទីកន្លែង។

ដូច Knight (2008, 25) បានបង្ហាញស្រាប់ "ហេតុផលនីមួយៗ បានចង្អុលតម្រង់ទៅប្រភេទនៃអត្ថប្រយោជន៍ ឬលទ្ធផលរំពឹងទុកផ្សេងៗដែលអ្នកចូលរួមគិតថា អាចទទួលបានពីកិច្ចប្រឹងប្រែងធ្វើអន្តរជាតូបនីយកម្ម"។ ប៉ុន្តែទន្ទឹមនឹងការទទួលស្គាល់នូវអត្ថប្រយោជន៍ទាំងនេះ មានមនុស្សជាច្រើន បានលើកឡើងថា ពិភពលោកត្រូវបានកំណត់ឡើងដោយវិសមភាព ហើយអន្តរជាតូបនីយកម្មនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ កើតមានឡើងដោយត្រូវមានការលះបង់ច្រើន។ យោងតាម Altbach and Knight (2007) និង Hoppers (2000) មូលនិធិធំៗសម្រាប់ការស្រាវជ្រាវ និងអាហារូបករណ៍ កន្លងមកផ្តោតជាសំខាន់ទៅលើគ្រឹះស្ថានឧត្តមសិក្សានៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិក កាណាដា និងប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ដែលនៅទីនោះមានធនធានបណ្ណាល័យ និងមន្ទីរពិសោធន៍យ៉ាងសម្បូរបែប និងមានមូលធនមនុស្សប្រកបដោយគុណភាពខ្ពស់។ ប្រទេសទាំងនោះ មើលឃើញនិស្សិតអន្តរជាតិបង់ថ្លៃជា ប្រភពចំណូលដ៏សំខាន់របស់ខ្លួន។ និស្សិតអន្តរជាតិបង់ថ្លៃមួយចំនួន ក្រោយមកក៏ក្លាយជាជនអន្តោប្រវេសន៍មានជំនាញខ្ពស់ សម្រាប់ជួយទ្រទ្រង់ការរីកចម្រើនសេដ្ឋកិច្ចក្នុងប្រទេសអភិវឌ្ឍន៍ទាំងនោះ ដោយសារពួកគេមើលឃើញថា ប្រទេសទាំងនោះមានលក្ខខណ្ឌការងារល្អប្រសើរជាងនៅក្នុងប្រទេសកំណើតរបស់ខ្លួន។ តួយ៉ាង សមាមាត្រនៃជនចំណាកស្រុកចេញពីប្រទេសអាស៊ាននានា ទៅកាន់បណ្តាប្រទេសសមាជិក អង្គការសម្រាប់សហប្រតិបតិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានកើនឡើងយ៉ាងគំហុកដល់ប្រមាណ ៦៦% ក្នុងរយៈពេល ១០ឆ្នាំ ពីត្រឹម ១.៦៧៩.៤៥៣នាក់ នៅឆ្នាំ២០០១ រហូតដល់ ២.៧៩១.៧២៧នាក់ នៅឆ្នាំ២០១១ (Batalova, Shymonyak, and Sugiyarto 2017, 14)។ បញ្ហាលំហូរចេញធនធានខួរក្បាលនេះ មានផលប៉ះពាល់អវិជ្ជមានខ្លាំងណាស់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃប្រទេសកំពុងអភិវឌ្ឍន៍។

ម្យ៉ាងទៀត អន្តរជាតូបនីយកម្មក្នុងលក្ខណៈជាមធ្យោបាយសម្រាប់លើកស្ទួយភាសាអង់គ្លេស ហើយនិងចំណេះដឹង វប្បធម៌ និងតម្លៃសីលធម៌របស់បស្ចឹមប្រទេស គឺជា ការខាតបង់មួយ

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (Altbach and Knight 2007; Altbach 2013)។ ឧទាហរណ៍ជាក់ស្ដែងមួយ គឺការផុសឡើងនាពេលថ្មីៗនូវ វគ្គបណ្ដុះបណ្ដាលតាមអនឡាញ (MOOCs)។ ថ្វីបើគេចាត់ទុកវាជាមធ្យោបាយពង្រីក លទ្ធភាពទទួលបានការអប់រំថ្នាក់ឧត្ដមសិក្សាជាសកលក្ដី MOOCs ភាគច្រើនមានលក្ខណៈតាមបែបបស្ចិមប្រទេស ដោយសារអ្នកផ្ដល់សេវាអប់រំធំៗភាគច្រើនស្ថិតនៅក្នុងប្រទេសអភិវឌ្ឍន៍ (Altbach 2014)។ ដោយមូលហេតុនេះ Altbach (2014) និង Hughes (2008) បានវែកញែកថា ក្នុងករណីខ្លះ អន្តរជាតូបនីយកម្ម គឺជាទម្រង់មួយនៃ អាណានិគមនិយមបែបថ្មី។ ស្រដៀងគ្នាដែរ Mazrui (1975) បានពិនិត្យពីផលប៉ះពាល់អវិជ្ជមាននៃ អន្តរជាតូបនីយកម្មឧត្ដមសិក្សានៅទ្វីបអាហ្វ្រិកក្នុងទសវត្សរ៍១៩៦០ និង១៩៧០ ហើយបានលើកឡើងថា វាគ្រាន់តែជាទម្រង់មួយនៃការពឹងផ្អែកផ្នែកវប្បធម៌ ហើយគាត់កត់សម្គាល់ឃើញថា គ្រឹះស្ថានឧត្ដមសិក្សានៅអាហ្វ្រិក ដើរតួនាទីជាក្រុមហ៊ុនពហុជាតិបរទេសដែលបម្រើផលប្រយោជន៍ឲ្យបស្ចិមប្រទេស ជាជាងបម្រើប្រជាជនអាហ្វ្រិក។ គាត់បានផ្ដល់យុទ្ធសាស្ត្រ បី សម្រាប់ប៉ះប៉ូវផលប៉ះពាល់អវិជ្ជមាននៃការពឹងផ្អែកផ្នែកវប្បធម៌នេះ។ ទី១ គឺ យុទ្ធសាស្ត្រធ្វើមូលដ្ឋានីយកម្ម តាមរយៈការផ្សារភ្ជាប់មុខវិជ្ជាក្នុងកម្មវិធីសិក្សានៅសាកលវិទ្យាល័យអាហ្វ្រិក ទៅនឹងវប្បធម៌ និងចំណេះដឹងក្នុងស្រុក។ គាត់ផ្ដល់គំនិតបន្ថែមថា ភាពស្ទាត់ជំនាញរបស់និស្សិតក្នុងផ្នែកភាសា ប្រវត្តិសាស្ត្រ នវិទ្យាផ្នែកសង្គមនិងវប្បធម៌ គួរតែជាលក្ខខណ្ឌចាំបាច់ដាច់ខាត សម្រាប់ការទទួលសិស្សឲ្យចូលរៀននៅសាកលវិទ្យាល័យ។ ទី២ គឺ យុទ្ធសាស្ត្រធ្វើពិពិធកម្មដែលអំពាវនាវឲ្យ (គ្រឹះស្ថានឧត្ដមសិក្សា) កសាងកម្មវិធីសិក្សាមួយមានលក្ខណៈសកលពិតៗ។ ក្នុងនេះ គាត់បានផ្ដល់យោបល់ថា សាកលវិទ្យាល័យអាហ្វ្រិក គួរផ្ដោតមិនត្រឹមតែទៅលើអារ្យធម៌អឺរ៉ុប និងអាហ្វ្រិកប៉ុណ្ណោះទេ ប៉ុន្តែគួរផ្ដោតទៅលើអារ្យធម៌ឥណ្ឌា ចិន និង អ៊ីស្លាមផងដែរ។ ទី៣ គឺ យុទ្ធសាស្ត្រទប់ទល់ការជ្រៀតចូល (នៃចំណេះដឹងនិងមនោគមវិជ្ជាបរទេស) តាមរយៈការបង្កើតក្រុមសីលធម៌ពិសេសមួយ សម្រាប់ភាពជាអ្នកសិក្សាស្រាវជ្រាវដែលអាចមានឥទ្ធិពលទៅលើ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនានាក្នុងពិភពលោក។

## វិធីសាស្ត្រ

ការសិក្សានេះ បានប្រើប្រាស់គំរូការស្រាវជ្រាវតាមបែបគុណភាពដែល Creswell (2012, 16) បានជជែកការពារថាជាវិធីសាស្ត្រសមស្របបំផុតសម្រាប់ការស្រាវជ្រាវពីបញ្ហាថ្មីៗ ឬប្រធានបទដែលមិនសូវមានការសិក្សាលើនោះ។ ក្នុងរយៈពេល ៦ ខែ (ពីខែសីហា ២០១៦ ដល់ មករា ២០១៧) ក្រុមស្រាវជ្រាវបានធ្វើសម្ភាសន៍ស៊ីជម្រៅចំនួន ១៤ ជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងសាកលវិទ្យាល័យកម្ពុជាចំនួន ៦ (៣ ជារបស់ឯកជន និង ៣ ជារបស់រដ្ឋ) នៅទីក្រុងភ្នំពេញ និងនៅតាមខេត្ត។ ការជ្រើសរើសអ្នកឆ្លើយសម្ភាសន៍ បានធ្វើឡើងតាមការដៅទុករបស់អ្នកស្រាវជ្រាវ ដោយផ្អែកលើកត្តាបទពិសោធន៍ និងការចូលរួមក្នុងសកម្មភាពអន្តរជាតូបនីយកម្មនៅតាមស្ថាប័នរបស់ពួកគាត់។ ក្រុមស្រាវជ្រាវ បានយកទិន្នន័យប្រមូលបានមកវិភាគតាមបែបគុណភាព ដើម្បីស្វែងយល់ពីបែបបទដែលអ្នកចូលរួមម្នាក់ៗបានកំណត់និយមន័យ និងយល់ឃើញពីការធ្វើអន្តរជាតូបនីយកម្មនៅកម្ពុជា។ ក្រុមស្រាវជ្រាវ បានប្រើរហស្សនាមដូចមានចុះក្នុង តារាង ៣ ដើម្បីរក្សាការសម្ងាត់ជូនដល់អ្នកចូលរួមក្នុងការសិក្សានេះ។

តារាង៣៖ បញ្ជីអ្នកចូលរួម និងតួនាទីក្នុងអង្គភាព

| អ្នកចូលរួម | ស្ថាប័នពាក់ព័ន្ធ | តួនាទី |
|---|---|---|
| SI1 | សាកលវិទ្យាល័យ A | សាកលវិទ្យាធិការរងសម្រាប់កិច្ចការសិក្សា |
| SI2 | សាកលវិទ្យាល័យ B | នាយករងសម្រាប់កិច្ចសហប្រតិបត្តិការ និងការស្រាវជ្រាវ |
| SI3 | សាកលវិទ្យាល័យ C | ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ |
| PI1 | សាកលវិទ្យាល័យ D | សាកលវិទ្យាធិការរងសម្រាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងកិច្ចការនិស្សិត |
| PI2 | សាកលវិទ្យាល័យ D | សាកលវិទ្យាធិការរងជាន់ខ្ពស់សម្រាប់កិច្ចការសិក្សា |
| PI3 | សាកលវិទ្យាល័យ D | នាយកកម្មវិធីសិក្សាអន្តរជាតិ |
| PI4 | សាកលវិទ្យាល័យ D | នាយក (សាកលវិទ្យាល័យសាខា) |
| PI5 | សាកលវិទ្យាល័យ D | នាយកជំនួយការ (សាកលវិទ្យាល័យសាខា) |
| PI6 | សាកលវិទ្យាល័យ D | នាយកជំនួយការរង (សាកលវិទ្យាល័យសាខា) |
| PI7 | សាកលវិទ្យាល័យ E | អ្នកសម្របសម្រួលកិច្ចការអន្តរជាតិ |
| PI8 | សាកលវិទ្យាល័យ E | នាយកផ្នែកស្រាវជ្រាវ |
| PI9 | សាកលវិទ្យាល័យ E | សាស្ត្រាចារ្យ |
| PI10 | សាកលវិទ្យាល័យ E | ប្រធានដេប៉ាតឺម៉ង់ថែទាំអ្នកជំងឺ |
| PI11 | សាកលវិទ្យាល័យ F | នាយករង (សាកលវិទ្យាល័យសាខា) |

រូបភាព១៖ ពាក្យប្រើនៅក្នុងចក្ខុវិស័យរបស់គ្រឹះស្ថានឧត្តមសិក្សាទាំង ៦ ដែលស្ថិតក្នុងការស្រាវជ្រាវនេះ




| ពាក្យ | ប្រេកង់ |
| --- | --- |
| ការអប់រំ | 8 |
| កម្ពុជា | 7 |
| គុណភាព | 6 |
| អន្តរជាតិ | 4 |
| ការស្រាវជ្រាវ | 4 |
| និស្សិត | 4 |
| បច្ចេកវិទ្យា | 3 |
| រដ្ឋាភិបាល | 3 |
| វិទ្យាសាស្ត្រ | 3 |
| សន្តិភាព | 3 |

ប្រភព: អ្នកនិពន្ធ

## លទ្ធផលរកឃើញ និងការពិភាក្សា

ក្នុងកំឡុងពេលប្រមូលទិន្នន័យ អ្នកចូលរួមបានផ្ដល់ចម្លើយផ្សេងៗគ្នាអំពីនិយមន័យរបស់ពាក្យ "អន្តរជាតូបនីយកម្ម" ដោយខ្លះបានលើកថា វាជាភាពជាដៃគូជាមួយស្ថាប័នឬសហសេវិកបរទេស អាហារូបករណ៍នៅក្រៅប្រទេស និងកម្មវិធីផ្លាស់ប្ដូរនិស្សិតនិងបុគ្គលិក កិច្ចសហការស្រាវជ្រាវ កម្មវិធីសិក្សាអន្តរជាតិ និងជាពិសេស ការប្រើភាសាអង់គ្លេសជាមធ្យោបាយសម្រាប់ការបង្រៀននិងរៀន។ តាមមតិរបស់អ្នកចូលរួម SI1 អន្តរជាតូបនីយកម្មសំដៅដល់ ការសិក្សានៅបរទេសរបស់និស្សិត និងបុគ្គលិកតាមរយៈ អាហារូបករណ៍ និងកម្មវិធីផ្លាស់ប្ដូរនិស្សិត និងបុគ្គលិក។ វាជា "អន្តរកម្មឥតព្រំដែន" ឬជា "អន្តរកម្មឆ្លងវប្បធម៌" ដែលជាប់ពាក់ព័ន្ធនឹងការចូលរួមនៅកម្រិតតំបន់ និងសកល។ ប៉ុន្តែ ចំណុចគួរឲ្យកត់សម្គាល់ដ៏សំខាន់មួយ គឺអ្នកចូលរួមភាគច្រើនហាក់ដូចជានិយាយត្រឹមតែការសិក្សាក្រៅប្រទេស និងការអនុម័តយកភាសាអង់គ្លេសមកប្រើក្នុងកម្មវិធីសិក្សាប៉ុណ្ណោះ។ មានអ្នកចូលរួមតិចនាក់ណាស់ដែលមានការយល់ដឹងទូលំទូលាយពី អន្តរជាតូបនីយកម្ម ដោយឲ្យនិយមន័យពាក្យនេះថាជា សកម្មភាពអន្តរជាតិច្រើនបែបយ៉ាង ទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ដូចអ្នកចូលរួម PI1 បានបញ្ជាក់ច្បាស់ "វាមិនមែនមានន័យថា យើងត្រូវតែចេញទៅក្រៅ[ប្រទេស] ដើម្បីចូលរួមសកម្មភាពអន្តរជាតូបនីយកម្មនោះទេ។ យើងក៏អាចធ្វើអន្តរជាតូបនីយកម្ម នៅក្នុងប្រទេសកម្ពុជាបានដូចគ្នាដែរ"។

សម្ភាសន៍ស៊ីជម្រៅ បានផ្ដល់គំនិតបន្ថែមទៀតថា កង្វះការយល់ដឹងពីអន្តរជាតូបនីយកម្ម នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា កើតមានជាសំខាន់ដោយសារ កង្វះយុទ្ធសាស្ត្រ និងគោលនយោបាយអន្តរជាតូបនីយកម្ម ទាំងនៅកម្រិតស្ថាប័ន និងកម្រិតជាតិ។ ចំណុចនេះ បានបង្ហាញយ៉ាងច្បាស់អំពីការតម្រង់ទិសនៃការអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជាសព្វថ្ងៃ ទោះបីពាក្យ "អន្តរជាតិ" មានចុះនៅក្នុងចក្ខុវិស័យរបស់សាកលវិទ្យាល័យ ៤ ក្នុងចំណោមសាកលវិទ្យាល័យ ៦ ដែលស្ថិតក្នុងការស្រាវជ្រាវនេះក្ដី។ រូបភាព១ បង្ហាញថា សមាសភាគអន្តរជាតិ ជាចំណែកដ៏សំខាន់មួយនៃចក្ខុវិស័យរបស់គ្រឹះស្ថានឧត្តមសិក្សាទាំងនោះ។

ទាក់ទងនឹងទស្សនៈវិជ្ជមានលើ ការធ្វើអន្តរជាតូបនីយកម្មវិញ ហេតុផលផ្នែកសិក្សាស្រាវជ្រាវ ត្រូវបានយកមកពិភាក្សាយ៉ាងទូលំទូលាយក្នុងការស្រាវជ្រាវនេះ។ អ្នកចូលរួម PI1 បានចង្អុលបង្ហាញថា សកម្មភាពអន្តរជាតូបនីយកម្មអាចជួយបង្កើនគុណភាពការបង្រៀននិងរៀន ក៏ដូចជា ជួយលើកមុខមាត់ស្ថាប័នរបស់គាត់ផងដែរ។ គាត់ផ្ដល់គំនិតបន្ថែមថា ស្ថាប័នរបស់គាត់ បានអនុម័តយកកម្មវិធីសិក្សា ដែលមានការទទួលស្គាល់ជាអន្តរជាតិ និងប្រើប្រាស់ភាសាអង់គ្លេស ជាមធ្យោបាយក្នុងការបង្រៀន ដើម្បីដើរឲ្យទាន់ការផ្លាស់ប្ដូរយ៉ាងលឿននៃ សាកលភាវូបនីយកម្ម។ អ្នកចូលរួមម្នាក់ទៀតមកពីសាកលវិទ្យាល័យរដ្ឋ ក៏បានយល់ស្របនឹងមតិលើកឡើងខាងលើ ហើយបានបន្ថែមទៀតថា ដៃគូអន្តរជាតិ អាចជួយកសាងហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការផ្សេងៗរបស់ស្ថាប័នគាត់ ក្នុងនោះមានទាំងមន្ទីរពិសោធន៍សម្រាប់ធ្វើការស្រាវជ្រាវ ដែលអាចមានតម្លៃខ្ពស់ហួសពីសមត្ថភាពរបស់ គ្រឹះស្ថានឧត្តមសិក្សាស្ទើរតែទាំងអស់នៅកម្ពុជា (SI1)។ ក្រៅពីហេតុផលផ្នែកសិក្សា នៅមានហេតុផលផ្នែកសង្គម-វប្បធម៌ទៀត ព្រោះមានអ្នកចូលរួមមួយចំនួនបានលើកឡើងពីឱកាសសម្រាប់ការចែករំលែកវប្បធម៌តាមរយៈ កម្មវិធីផ្លាស់ប្ដូរនិស្សិត ជាដើម។ អ្នកចូលរួម PI1 បានលើកថា "ការទាក់ទាញនិស្សិតអន្តរជាតិ ឲ្យចូលមកសិក្សាក្នុងសកលវិទ្យាល័យរបស់

យើងកាន់តែច្រើន នឹងផ្ដល់ឱកាសឲ្យនិស្សិតយើងរៀនសូត្របានច្រើនថែមទៀតអំពីវប្បធម៌បរទេស ហើយក្នុងពេលជាមួយគ្នានិស្សិតយើងក៏អាចចែករំលែកវប្បធម៌ និងប្រពៃណីរបស់យើងទៅដល់និស្សិតបរទេសដែរ"។ គាត់គិតថា ការយល់ដឹងអន្តរវប្បធម៌មានសារៈសំខាន់បំផុត ដើម្បីលើកស្ទួយការយោគយល់គ្នាទៅវិញទៅមក និងសន្តិភាពក្នុងចំណោមប្រជាជាតិទាំងឡាយ។ មិនតែប៉ុណ្ណោះ ការនាំយកនិស្សិត និងសាស្ត្រាចារ្យអន្តរជាតិឲ្យបានកាន់តែច្រើនមកក្នុងសាកលវិទ្យាល័យ ក៏ត្រូវចំណាយអស់តិចជាងការបញ្ជូននិស្សិតទៅបរទេសដែរ។

ហេតុផលពីរផ្សេងទៀត ត្រូវបានលើកយកមកបកស្រាយតិចតួចណាស់ក្នុងអំឡុងពេលនៃការសិក្សានេះ។ ហេតុផលផ្នែកនយោបាយ បានផុសឡើងតែក្នុងពេលសម្ភាសន៍ជាមួយអ្នកធ្វើការក្នុងវិស័យសាធារណៈ ដោយពួកគាត់លើកឡើងពីកម្មវិធីជំនួយផ្នែកអប់រំដែលទទួលបានមូលនិធិពី ទីភ្នាក់ងាររដ្ឋាភិបាលនានា ក្នុងន័យលើកកម្ពស់ទំនាក់ទំនងរវាងប្រទេសមួយ នឹងប្រទេសមួយ។ ក្នុងការពិភាក្សាពីហេតុផលសេដ្ឋកិច្ចវិញ មានការផ្ដោតតែលើការចូលក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលបានចាប់ដំណើរការតាំងពីខែធ្នូ ២០១៥ មក ដើម្បីលើកកម្ពស់លំហូរដោយសេរីនៃកម្លាំងពលកម្ម មូលធន និងទំនិញ ក្នុងចំណោមប្រទេសនានានៅក្នុងតំបន់។ ដូចនេះ កម្ពុជាត្រូវធ្វើការកាន់តែខ្លាំងឡើង ដើម្បីផលិតធនធានមនុស្សឲ្យមានសមត្ថភាពខ្ពស់ ដែលអាចជួយលើកកម្ពស់កម្លាំងប្រកួតប្រជែងរបស់កម្ពុជាទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក។ ក្រៅពីនេះ មានការពិភាក្សាតិចតួចណាស់ ពី យុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្នុងការធ្វើអន្តរជាតូបនីយកម្ម ដូចជា ការទាក់ទាញនិស្សិតបរទេស និងអ្នកស្រាវជ្រាវ ដើម្បីជួយបង្កើនប្រាក់ចំណូលរបស់សាកលវិទ្យាល័យជាដើម។ យើងទទួលស្គាល់គ្រប់គ្នាថា បញ្ហានេះ បណ្ដាលមកពីកង្វះគុណភាព និងការខ្សត់ធនធានរបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាភាគច្រើន។ ម្យ៉ាងទៀត អ្នកចូលរួមជាច្រើនរូបបានលើកមតិថា មានសកលវិទ្យាល័យតិចតួចណាស់ដែលផ្ដល់កម្មវិធីសិក្សាជាភាសាអង់គ្លេស ហើយនេះជារបាំងដ៏ធំមួយរារាំងស្ថាប័នឧត្តមសិក្សាកម្ពុជា ក្នុងការចូលរួមឲ្យបានកាន់តែច្រើនជាមួយនឹងសមភាគីបរទេសនានា។

ថ្វីបើមានទស្សនៈវិជ្ជមាន ដូចលើកឡើងនៅខាងលើក្ដី ក៏មានអ្នកចូលរួមខ្លះបានរិះគន់ដល់អន្តរជាតូបនីយកម្មដែរ។ អ្នកចូលរួម SI1 អះអាងថា ស្ថាប័នរបស់គាត់មិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីចូលរួមជាមួយសហគមន៍សិក្សាស្រាវជ្រាវក្នុងតំបន់ និងអន្តរជាតិទេ ដោយសារកង្វះថវិកា និងសមត្ថភាពរបស់ស្ថាប័ន ហើយរហូតមកទល់បច្ចុប្បន្ន សាកលវិទ្យាល័យរបស់គាត់ បានកំណត់កម្មវិធីសិក្សារបស់ខ្លួនត្រឹមតែសម្រាប់ តម្រូវការក្នុងស្រុកប៉ុណ្ណោះ។ តាមយោបល់គាត់ ក្នុងដំណើរការ AEC នេះ ការចូលរួមធ្វើអន្តរជាតូបនីយកម្មគឺមិនអាចជៀសផុតទេ ប៉ុន្តែបើសិនគ្មានការរៀបចំ និងការត្រៀមខ្លួនរួចរាល់ ស្ថាប័នរបស់គាត់នឹងត្រូវរងសម្ពាធពីបរទេស ឲ្យទទួលយកចំណេះដឹង និងមនោគមវិជ្ជាពីខាងក្រៅ។ អ្នកចូលរួម PI1 មានគំនិតដូចគ្នាដោយអះអាងថា នៅកម្ពុជា ជាការធម្មតាទេដែលសាស្ត្រាចារ្យ ឬគ្រូបង្រៀន ចម្លងឯកសារ និងខ្លឹមសារផ្សេងៗពីបរទេស [ដោយគ្មានការកែតម្រូវឲ្យត្រូវនឹងបរិបទក្នុងប្រទេស] សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន។

ម្យ៉ាងទៀត កម្មវិធីអន្តរជាតិមួយចំនួន គឺត្រូវបានតម្រង់ទិសជាស្រេចពីម្ចាស់ជំនួយ ដោយផ្ដល់លទ្ធភាពតិចតួចបំផុតឲ្យមានការកែតម្រូវទៅតាមបរិបទក្នុងស្រុក (អ្នកចូលរួម SI2)។ អ្នកចូលរួមខ្លះក៏បានលើកនូវ ក្ដីបារម្ភពីការប្រើប្រាស់កាន់តែច្រើនឡើងនូវ ភាសាអង់គ្លេស និងភាសាផ្សេងៗទៀត ដូចជា ចិន កូរ៉េ និង ជប៉ុន ជាជាងភាសាក្នុងស្រុក ដោយវានឹងមានផលប៉ះពាល់អវិជ្ជមានដល់ វប្បធម៌ ចំណេះដឹង និងតម្លៃរបស់ជាតិ។

## ការផ្ដល់មតិ

ការពិភាក្សាខាងលើ បានបង្ហាញថា អន្តរជាតូបនីយកម្មនៅតែជាគំនិតថ្មីមួយសម្រាប់កម្ពុជា ដោយមនុស្សភាគច្រើននៅតែផ្សារភ្ជាប់វាទៅនឹងទម្រង់បែបប្រពៃណីនៃពាក្យនេះ ដូចជា ការសិក្សាក្រៅប្រទេស ឬការប្រើភាសាបរទេសជាមធ្យោបាយក្នុងការបង្រៀន។ ខណៈដែលអ្នកចូលរួមភាគច្រើនបានមើលឃើញអន្តរជាតូបនីយកម្មជាឱកាសល្អ ក្ដីបារម្ភពីបញ្ហា ដូចជា ឥទ្ធិពលគ្របដណ្ដប់វប្បធម៌ ភាសា ចំណេះដឹង និងមនោគមវិជ្ជាផ្សេងៗរបស់បរទេស ក៏មានលើកឡើងដែរ។ ខាងក្រោមនេះ ជាមតិយោបល់មួយចំនួនរបស់អ្នកស្រាវជ្រាវ ដើម្បីចូលរួមជួយរុញច្រានឧត្តមសិក្សានៅកម្ពុជាឲ្យមានការធ្វើអន្តរជាតូបនីយកម្ម៖

ទី១ ដោយហេតុថា នៅមានមនុស្សជាច្រើនមិនទាន់បានយល់ដឹងពីគោលគំនិតនៃ អន្តរជាតូបនីយកម្មឧត្តមសិក្សា និងសារៈសំខាន់របស់វានោះ គឺជាការចាំបាច់បំផុត ដែលរដ្ឋាភិបាលមានផ្ដល់នូវ គោលការណ៍ណែនាំទូទៅ និងយុទ្ធសាស្ត្រអន្តរជាតូបនីយកម្ម ដល់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ ក្នុងនេះ គួរមានគំនិតផ្ដួចផ្ដើមផ្សេងៗ តាំងពីការផ្ដល់អាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស រហូតដល់ការបង្កើតកម្មវិធីសម្រាប់ទាក់ទាញជនបរទេស ដែលមានទេពកោសល្យ និងជនកម្ពុជាដែលបានទទួលការអប់រំនៅក្រៅប្រទេសឲ្យចូលមកកម្ពុជា ដើម្បីជួយកសាងប្រព័ន្ធអប់រំរបស់កម្ពុជាឡើងវិញ។

ទី២ ច្បាស់ហើយ គ្រឹះស្ថានឧត្តមសិក្សាជាច្រើននៅកម្ពុជានៅមិនទាន់បានយល់ច្បាស់ពី អន្តរជាតូបនីយកម្មកម្មវិធីសិក្សា ហើយមិនសូវមានស្ថាប័នឧត្តមសិក្សានៅកម្ពុជាច្រើនទេ ដែលបានអនុវត្តកម្មវិធីប្រភេទនេះ។ វាជាការពិតដែលគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាភាគច្រើនបានអនុម័តយកកម្មវិធីសិក្សា និងឯកសារបង្រៀននិងរៀនពីបរទេស ដោយមានការកែសម្រួលឲ្យស៊ីនឹងបរិបទក្នុងស្រុកតែបន្តិចបន្តួចប៉ុណ្ណោះ។ ការធ្វើបែបនេះ បានចោទជាបញ្ហាដ៏ធ្ងន់ធ្ងរមួយពីភាពពាក់ព័ន្ធនៃ ប្រព័ន្ធអប់រំនៅកម្ពុជា (ឬបញ្ហាគ្របដណ្ដប់លើការសិក្សាស្រាវជ្រាវ ឬភាពពឹងផ្អែកផ្នែកវប្បធម៌)។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ កម្ពុជាគួរអនុវត្តតាមយុទ្ធសាស្ត្របីរបស់ Mazrui គឺមាន យុទ្ធសាស្ត្រធ្វើមូលដ្ឋានីយកម្ម យុទ្ធសាស្ត្រធ្វើពិពិធកម្ម និងយុទ្ធសាស្ត្រទប់ទល់ការជ្រៀតចូល។

កម្ពុជាគួរកែសម្រួលចំណេះដឹងបរទេស ឲ្យសមស្របទៅនឹងបរិបទក្នុងស្រុក។ និស្សិតសាកលវិទ្យាល័យម្នាក់ៗ ទោះក្នុងមុខជំនាញអ្វីក៏ដោយ គួរតែមានការយល់ដឹងច្បាស់លាស់ពីវប្បធម៌ ភាសា និង ប្រវត្តិសាស្ត្រកម្ពុជា។ គ្រឹះស្ថានឧត្ដមសិក្សាកម្ពុជា គួរដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ខ្លួននូវ ចំណេះដឹងពីប្រទេសឯទៀតនៅអាស៊ាន និងជុំវិញពិភពលោក ហើយកម្ពុជាក៏គួរកសាង(ឡើងវិញ)នូវប្រព័ន្ធអាហារូបករណ៍របស់ខ្លួន ជាពិសេសតាមរយៈការបង្កើតនិងគួបផ្សំភាពតឹងរឹងនៃការស្រាវជ្រាវជាមួយនឹង ចំណេះដឹងក្នុងស្រុកក្នុងមុខវិជ្ជាផ្សេងៗ ព្រមទាំងលើកស្ទួយវាជាមួយគ្នានឹង ភាសា និងវប្បធម៌កម្ពុជា នៅកម្រិតអន្តរជាតិ។

ឯកសារស្រាវជ្រាវនេះ ផ្ដល់នូវទិដ្ឋភាពទូទៅនៃការឲ្យនិយមន័យ និងការយល់ឃើញផ្សេងៗ លើអន្តរជាតូបនីយកម្មឧត្តមសិក្សានៅកម្ពុជា។ ដោយផ្ដែកលើការសិក្សាជាមូលដ្ឋាននេះ ការស្រាវជ្រាវនាពេលអនាគត អាចពិនិត្យឲ្យកាន់តែស៊ីជម្រៅថែមទៀតពី ខ្លឹមសារ និងហេតុផលនៃអន្តរជាតូបនីយកម្ម ដោយវិភាគតាមទស្សនៈរបស់អ្នកពាក់ព័ន្ធដទៃទៀត។ ទិដ្ឋភាពផ្សេងៗទៀតនៃអន្តរជាតូបនីយកម្មនៅកម្ពុជា ដូចជា ភាពចល័តចេញទៅក្រៅនិងចូលមកក្នុងប្រទេស ការប្រើប្រាស់ភាសាបរទេសនិងកម្មវិធីសិក្សាអន្តរជាតិ ការបង្កើតសាខារបស់គ្រឹះស្ថានឧត្តមសិក្សាបរទេសនៅកម្ពុជា និងភាពជាដៃគូឆ្លងដែនក្នុងការបង្រៀន និងការស្រាវជ្រាវ គួរមានការសិក្សាឲ្យបានស៊ីជម្រៅជាងនេះ។

## ឯកសារយោង


Altbach, Philip G. 2013. "The Imperial Tongue: English as the Dominating Academic Language." In *The International Imperative in Higher Education*, 1–6. Global Perspectives on Higher Education Vol 27. Rotterdam: Sense Publishers. http://link.springer.com/chapter/10.1007/978-94-6209-338-6_1.

Altbach, Philip G. 2014. "MOOCs as Neocolonialism: Who Controls Knowledge?" *International Higher Education* 75 (March): 5–7. doi:10.6017/ihe.2014.75.5426.

Altbach, Philip G., and Jane Knight. 2007. "The Internationalization of Higher Education: Motivations and Realities." *Journal of Studies in International Education* 11 (3-4): 290–305. doi:10.1177/1028315307303542.

Batalova, Jeanne, Andriy Shymonyak and Guntur Sugiyarto. 2017. "Firing Up Regional Brain Networks: The Promise of Brain Circulation in the ASEAN Economic Community." Mandaluyong City, Philippines: Asian Development Bank. https://www.adb.org/publications/regional-brain-networks-asean.

Clayton, Thomas. 2006. *Language Choice in a Nation under Transition: English Language Spread in Cambodia*. Language Policy Vo. 5. Springer Science+Business Media.

Creswell, John W. 2012. *Educational Research: Planning, Conducting, and Evaluating Quantitative and Qualitative Research*. 4th ed. Boston, MA: Pearson.

Hawawini, Gabriel. 2016. *The Internationalization of Higher Education and Business Schools*. Springer Briefs in Business. Singapore: Springer. http://www.springer.com/gp/book/9789811017551.

Hoppers, Catherine A. Odora. 2000. "The Centre-Periphery in Knowledge Production in the Twenty-First Century." *Compare: A Journal of Comparative and International Education* 30 (3): 283–91. doi:10.1080/713657471.

Hughes, Rebecca. 2008. "Internationalisation of Higher Education and Language Policy: Questions of Quality and Equity." *Higher Education Management and Policy* 20 (1): 1–18. doi:10.1787/hemp-v20-art6-en.

Knight, Jane. 2004. "Internationalization Remodeled: Definition, Approaches, and Rationales." *Journal of Studies in International Education* 8 (1): 5–31. doi:10.1177/1028315303260832.

Knight, Jane. 2008. *Higher Education in Turmoil: The Changing World of Internationalization*. Global Perspectives on Higher Education Vol 13. Rotterdam: Sense Publishers. https://www.sensepublishers.com/media/475-higher-education-in-turmoil.pdf.

Larsen, Marianne A. 2016. *Internationalization of Higher Education: An Analysis through Spatial, Network, and Mobilities Theories*. New York: Palgrave Macmillan. http://www.palgrave.com/gb/book/9781137533449.

Mazrui, Ali. 1975. "The African University as Multinational Cooperation: Problems of Penetration and Dependency." *Harvard Educational Review* 45 (2): 191–210.

Pit, Chamnan, and David Ford. 2004. "Cambodian Higher Education: Mixed Visions." In *Asian Universities: Historical Perspectives and Contemporary Challenges*, edited by Philip G. Altbach and Toru Umakoshi, 333–62. Baltimore, MA: John Hopkins University Press.

UIS (UNESCO Institute for Statistics). 2016. "Global Flow of Tertiary-Level Students." http://glossary.uis.unesco.org/Education/Pages/international-student-flow-viz.aspx.

UIS. 2017. "Education : Outbound Internationally Mobile Students by Host Region." May. http://data.uis.unesco.org/#.

Wit, Hans de. 2002. *Internationalization of Higher Education in the United States of America and Europe: A Historical, Comparative, and Conceptual Analysis*. Westport, CT: Greenwood Publishing Group.

Wit, Hans de, Fiona Hunter, Laura Howard and Eva Egron-Polak. 2015. "Internationalisation of Higher Education." Brussels: European Parliament's Committee on Culture and Education. http://www.europarl.europa.eu/studies.

# ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្រដល់សហគមន៍អេកូទេសចរណ៍នៅកម្ពុជា៖ វិធីសាស្ត្រ ម៉ូដែលសមីការជាប្រព័ន្ធ

### សេចក្តីផ្តើម

អ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តជាក់ស្តែង បានទទួលស្គាល់ជាយូរមកហើយថា ឥរិយាបថ និងការចូលរួមរបស់អ្នកស្រុក ជាកត្តាគន្លឹះពីរដែលជះឥទ្ធិពលដល់ជោគជ័យ និងចីរភាពនៃការអភិវឌ្ឍទេសចរណ៍។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ (CBET) ត្រូវបានគេផ្តួចផ្តើមគំនិត និងអនុវត្តនៅកម្ពុជា តាំងពីដើមទសវត្សរ៍១៩៩០ ក្នុងទម្រង់ជា គម្រោងដាក់បញ្ចូលគ្នានូវការអភិរក្ស និងអភិវឌ្ឍន៍ (integrated conservation and development projects: ICDPs) ដើម្បីថែរក្សាធនធានធម្មជាតិ និងបង្កើតចំណូលបន្ថែមសម្រាប់ប្រជាជនមូលដ្ឋាន។ ថ្វីបើគម្រោងអេកូទេសចរណ៍ផ្អែកលើសហគមន៍ ជាច្រើនមានជោគជ័យ និងចីរភាពល្អក្តី ប៉ុន្តែក៏មានច្រើនដែរ ដែលមិនអាចបន្តដំណើរការបានយូរអង្វែង។ កត្តាកំណត់មួយនៃបរាជ័យនេះ អាចជាការចូលរួមកម្រិតទាប ឬមិនចូលរួម និងឥរិយាបថអវិជ្ជមានរបស់អ្នកស្រុក។ Carter et al. (2015) បានរកឃើញថា ២៣% នៃការសិក្សាមុនៗ និងឯកសារមានស្រាប់ស្តីពីទេសចរណ៍មានចីរភាពនៅកម្ពុជា ផ្តោតលើអេកូទេសចរណ៍។ ប៉ុន្តែក្នុងនេះ ឥរិយាបថរបស់អ្នកស្រុកចំពោះ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយនិង ទំនាក់ទំនងរវាងការចូលរួម ជាមួយនឹងឥរិយាបថរបស់អ្នកស្រុក នៅមានការសិក្សាតិចតួចណាស់នៅកម្ពុជា។ ដូច្នេះ ដើម្បីបានយល់ដឹងកាន់តែប្រសើរ ពីតួនាទីនៃការចូលរួមរបស់អ្នកស្រុកក្នុងការកែលំអឥរិយាបថរបស់ខ្លួន ចំពោះអេកូទេសចរណ៍ផ្អែកលើសហគមន៍ ការសិក្សានេះព្យាយាមកំណត់ពី ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្ររបស់គាត់ដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

### ក្របខ័ណ្ឌគោលគំនិត

ក្រុមស្រាវជ្រាវបានប្រើប្រាស់ ម៉ូដែលសមីការជាប្រព័ន្ធ (structural equation modelling: SEM) ដើម្បីសិក្សាពីទំនាក់ទំនងរវាងកត្តាជាប់ពាក់ព័ន្ធនានា ដូចមានបង្ហាញក្នុងរូបភាព A1 នៃឧបសម្ព័ន្ធ។ ពីដំបូង ក្រុមស្រាវជ្រាវបានបង្កើតសម្មតិកម្មមួយសំណុំ ដោយផ្អែកលើការសិក្សាមុនៗនិងឯកសារមានស្រាប់ និងទ្រឹស្តីសំខាន់ៗមួយចំនួន។ សម្មតិកម្មទាំងនោះមានបញ្ជាក់នៅខាងក្រោម។

### ការចូលរួមដោយមានកម្រៃ

នៅក្នុងអេកូទេសចរណ៍ផ្អែកលើសហគមន៍ តាមធម្មតាគេប្រើការចូលរួមដោយមានកម្រៃ (remunerative participation: RPART) ជាមធ្យោបាយលើកទឹកចិត្ត សម្រាប់ជំរុញអ្នកស្រុកឲ្យចូលរួមក្នុង អេកូទេសចរណ៍ផ្អែកលើសហគមន៍ ដើម្បីជួយថែរក្សាធនធានធម្មជាតិ និងជួយគាំទ្រដល់គម្រោង អេកូទេសចរណ៍ផ្អែកលើសហគមន៍។ RPART វាស្រដៀងគ្នានឹង ការពឹងផ្អែកផ្នែកសេដ្ឋកិច្ចរបស់អ្នកស្រុកទៅលើទេសចរណ៍ និងជាកត្តាមួយដែលមានគេសិក្សាច្រើន។ កម្រិតនៃ RPART គឺអាចដូចគ្នានឹងកម្រិតនៃការពឹងផ្អែកទៅលើទេសចរណ៍។ គេអាចមើលឃើញយ៉ាងងាយថា អ្នកស្រុកដែលមានការពឹងផ្អែកផ្នែកសេដ្ឋកិច្ចទៅលើទេសចរណ៍ អាចមានឥរិយាបថវិជ្ជមានចំពោះការអភិវឌ្ឍទេសចរណ៍។ ការសិក្សារបស់ Pizam (1978) and Vesey and Dimanche (2000) បានគាំទ្រដល់មតិនេះ។ ដោយផ្អែកលើការសិក្សាទាំងនោះ និងមតិផ្ទាល់របស់ក្រុមស្រាវជ្រាវ ក្រុមស្រាវជ្រាវបានលើកជា សម្មតិកម្ម ៤ ឡើង៖

H1. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ការចូលរួមដោយគ្មានកម្រៃ (non- remunerative participation: NRPART)។

H2. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ទស្សនៈពីផលប៉ះពាល់នៃអេកូទេសចរណ៍ទៅលើ ទ្រព្យទ្រទ្រង់ជីវភាព (perceived impacts on livelihood assets: PILA)។

H3. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ទស្សនៈពីផលប៉ះពាល់នៃអេកូទេសចរណ៍ទៅលើ កម្រិតជីវភាព (perceived impacts on livelihood outcome: PILO)។

H4. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ការគាំទ្រចំពោះអេកូទេសចរណ៍ (support for CBET: SUPPORT)។

### ការចូលរួមដោយគ្មានកម្រៃ

ការសិក្សាជាច្រើនបានរកឃើញថា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍ ការគ្រប់គ្រង ឬការធ្វើសេចក្តីសម្រេចចិត្ត វាជះឥទ្ធិពលវិជ្ជមានទៅលើទស្សនៈ ពីផលប៉ះពាល់នៃទេសចរណ៍។ Lankford (1994) បានលើកគំនិតថា បើសិនមានការគិតគូរដល់មតិយោបល់ និងការចូលរួមរបស់អ្នកស្រុក ពួកគាត់ទំនងជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ គំនិតនេះមានការគាំទ្រពី Lee (2013) ដែលបង្ហាញថា ការចូលរួមរបស់សហគមន៍

---

អត្ថបទនេះរៀបរៀងដោយ វ៉ែន សីហា ជាអ្នកស្រាវជ្រាវក្នុងផ្នែកសេដ្ឋកិច្ចនៃវិទ្យាស្ថាន CDRI និង Koichi Usami ជាសាស្ត្រាចារ្យនៅ Graduate School of International Development, Nagoya University, Japan។ សូមយោងឯកសារនេះថា៖ Ven Seyhah and Koichi Usami. 2017. "The Effects of Residents' Participation on Their Perception of and Support for Community-Based Ecotourism in Cambodia: A Structural Equation Modeling Approach." *Cambodia Development Review* 21 (1): 8-13.

រូបភាព ១៖ ម៉ូដែលតាមទ្រឹស្តី




ប្រភព៖ ការសិក្សារបស់អ្នកនិពន្ធលើឯកសារមានស្រាប់
កំណត់សំគាល់៖ H មានន័យថា សម្មតិកម្ម

វាជាប់ទាក់ទងជាវិជ្ជមានជាមួយនឹង ការគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ ដោយផ្អែកលើការសិក្សាមុនៗ និងឯកសារមានស្រាប់ទាំងនេះ ក្រុមស្រាវជ្រាវបានលើកជាសម្មតិកម្មដូចខាងក្រោម៖

H5. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILA។
H6. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។
H7. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។

### *ផលប៉ះពាល់តាមទស្សនៈរបស់អ្នកស្រុក*

ការសិក្សាភាគច្រើនក្នុងពេលកន្លងមក បានវាយតម្លៃពីផលប៉ះពាល់តាមទស្សនៈរបស់អ្នកស្រុក ដោយផ្អែកលើទិដ្ឋភាពសេដ្ឋកិច្ច សង្គម និង បរិស្ថាន។ គួរកត់សំគាល់ថា សូចនាករទាំងនេះ វាសមស្របសម្រាប់ការវាយតម្លៃលើតំបន់ទេសចរណ៍ខ្នាតធំ។ ប៉ុន្តែការសិក្សានេះផ្តោតលើ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ដែលគ្រប់គ្រងដោយប្រជាជនក្នុងមូលដ្ឋាន និងជារឿយៗមានជំនួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផង។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ មានគោលដៅជួយលើកស្ទួយជីវភាពប្រជាជន និងថែរក្សាធនធានធម្មជាតិក្នុងមូលដ្ឋាន។ ដូច្នេះហើយ ការសិក្សានេះក៏បានពិនិត្យពីផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ យោងតាមទស្សនៈរបស់អ្នកស្រុកទៅលើ ទ្រព្យទ្រទ្រង់ជីវភាព (PILA) និង កម្រិតជីវភាព (PILO)។ ទ្រព្យទ្រទ្រង់ជីវភាព រួមមាន ទ្រព្យស្នូល ៥ ប្រភេទ ដែលជីវភាពប្រជាជនត្រូវពឹងផ្អែកលើវា។ ដោយឡែក កម្រិតជីវភាព គឺជាលទ្ធផលនៃសកម្មភាពដោះស្រាយជីវភាព និងមានទម្រង់ជា កំណើនប្រាក់ចំណូល កំណើនសុខមាលភាព ការថយចុះភាពងាយរងគ្រោះ ការកែលំអសន្តិសុខស្បៀង និងការប្រើប្រាស់កាន់តែមានចីរភាពនូវ មូលដ្ឋានធនធានធម្មជាតិ (DFID 1999)។ ដោយសារទ្រព្យទ្រទ្រង់ជីវភាព វាជាគ្រឹះដើម្បីសម្រេចបាន កម្រិតជីវភាពល្អប្រសើរ ដូច្នេះ PILA ទំនងជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។

ទ្រឹស្តីនៃ ការដោះដូរគ្នាក្នុងសង្គម (social exchange theory: SET) កន្លងមក គេបានយកមកប្រើយ៉ាងទំលំទូលាយក្នុងការសិក្សាពីឥរិយាបថរបស់អ្នកស្រុក ចំពោះការអភិវឌ្ឍទេសចរណ៍។ SET អះអាងថា បើសិនអ្នកស្រុក មានទស្សនៈថា ទេសចរណ៍ មាន ផលប៉ះពាល់វិជ្ជមាន មិនមែនផលប៉ះពាល់អាក្រក់ ដែលមិនអាចទទួលយកបានទេនោះ ពួកគាត់ទំនងជាជួយគាំទ្រវា។ ផ្អែកលើការអះអាងនេះ អ្នកសិក្សាស្រាវជ្រាវជាច្រើននាក់ បានរកឃើញថា ផលប៉ះពាល់តាម ទស្សនៈរបស់អ្នកស្រុក គឺជាដើមចមនៃការគាំទ្រដល់ ការអភិវឌ្ឍទេសចរណ៍។ ដូច្នេះ គេអាចបង្កើតជាសម្មតិកម្មដូចតទៅ៖

H8. PILA ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។
H9. PILA ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។
H10. PILO ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។

សម្មតិកម្ម H1 និង H7 ចែងថា RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ NRPART ដែលបន្ទាប់មកក៏ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។ តាមនេះ RPART ទំនងជះឥទ្ធិពលដោយប្រយោល និងវិជ្ជមានដល់ SUPPORT ដោយមាន NRPART ជាកត្តាជួយសម្រួល (H11)[1]។ ស្រដៀងគ្នាដែរ ផ្អែកតាមសម្មតិកម្មផ្សេងៗទៀត គឺទំនងជា RPART និង NRPART ជះឥទ្ធិពលដោយប្រយោល និងវិជ្ជមានដល់ SUPPORT ដោយមាន PILA និង PILO ជាកត្តាជួយសម្រួល (H11 និង H13)។

## វិធីសាស្ត្រសិក្សា

### *តំបន់សិក្សា*

ការសិក្សានេះបានធ្វើឡើងនៅឃុំជីផាត់ ក្នុងតំបន់ព្រៃការពារភ្នំក្រវាញភាគខាងត្បូង ក្នុងខេត្តកោះកុង។ យោងតាមមូលដ្ឋានទិន្នន័យរបស់ឃុំ នៅឆ្នាំ២០១០ ឃុំជីផាត់មានប្រជាជនសរុប ៥៤៩ គ្រួសារ ក្នុងនោះ ៦៩% មានមុខរបរចម្បងដាំដុះស្រូវ, ១៣% មានមុខរបរចម្បងដាំដំណាំផ្សេងៗនិងបន្លែ ធ្វើនេសាទ និងចិញ្ចឹមសត្វ, ហើយ ៤,១% ប្រមូលអនុផលព្រៃឈើ។ សហគមន៍អេកូទេសចរណ៍ជីផាត់ បានកកើតឡើងក្នុងឆ្នាំ២០០៧ ដោយមានជំនួយគាំទ្រពីអង្គការ Wildlife Alliance (សម្ព័ន្ធភាពការពារសត្វព្រៃ) ដើម្បីការពារធនធានធម្មជាតិក្នុងមូលដ្ឋាន និងកែលំអជីវភាពរស់នៅរបស់អ្នកស្រុក។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ មានគណៈកម្មាធិការគ្រប់គ្រងមួយជ្រើសតាំងឡើងតាមការបោះឆ្នោត និងមានសមាជិកចំនួន ១៦៧គ្រួសារ ដែល

1 ឥទ្ធិពលដោយប្រយោលនៃ (H11, H12, H13) មិនអាចបង្ហាញក្នុង រូបភាព១ បានទេ ព្រោះផ្លូវរបស់វាត្រូវបានបាំងជិតអស់ដោយឥទ្ធិពលដោយផ្ទាល់។

រូបភាព ២៖ ម៉ូដែលផ្ទៀងផ្ទាត់




ប្រភព៖ លទ្ធផលនៃការវិភាគរបស់អ្នកនិពន្ធ ឆ្នាំ២០១៤
កំណត់សំគាល់៖ ( ) denotes standardised coefficients; significant at p-value < 0.01*** and <0.05 **.

ផ្លាស់វេនគ្នាផ្តល់សេវាឲ្យទេសចរ ដូចជា ការស្នាក់តាមផ្ទះអ្នកភូមិ ផ្ទះសំណាក់ មគ្គុទ្ទេសន៍ ការដឹកជញ្ជូន ម្ហូបអាហារ ជាដើម។

### ការប្រមូលទិន្នន័យ

ទិន្នន័យបានប្រមូលយកពីអ្នកស្រុក ២០០នាក់ ក្នុង ៤ភូមិ នៅឃុំជីផាត់ ដែលមានទាំងសមាជិក និងអ្នកមិនមែនសមាជិកនៃសហគមន៍អេកូទេសចរណ៍ជីផាត់។ អង្កេតបានធ្វើឡើងក្នុងខែឧសភា ២០១៤ ដោយប្រើបញ្ជីសំណួររៀបរយសម្រាប់ធ្វើសម្ភាសន៍។ សំណាកត្រូវបានជ្រើសយកតាមវិធីរើសសំណាកសមាមាត្រ (proportionate sampling) ដើម្បីបានអ្នកឆ្លើយសម្ភាសន៍ចម្រុះគ្នា ពីក្នុងភូមិទាំង ៤។

### ការវិភាគទិន្នន័យ

ម៉ូដែលសមីការជាប្រព័ន្ធ (structural equation modelling: SEM) ដែលមានពីរជំហាន ត្រូវបានបង្កើតឡើង ដើម្បីធ្វើតេស្តម៉ូដែលតាមទ្រឹស្តី (theoretical model) ដូចមានបង្ហាញក្នុង Figure A1 នៃឧបសម្ព័ន្ធ។ ជំហានទី១ គឺ ការបង្កើតម៉ូដែលវាស់វែង (measurement model) ដើម្បីផ្ទៀងផ្ទាត់មើលថា សូចនាករ (observed variables) ពិតជាវង្វាស់សមរម្យសម្រាប់អញ្ញាតអរូបិយ (latent variable) របស់ពួកវាមែន។ វិធីសាស្ត្រវិភាគកត្តាបញ្ជាក់ (confirmatory factor analysis: CFA) បានយកមកអនុវត្ត ដើម្បីធ្វើតេស្តបញ្ជាក់ពីភាពស៊ីគ្នាល្អ (fitness) នៃម៉ូដែលវាស់វែង ដែលក្នុងនោះ អញ្ញាតអរូបិយទាំង ៥ (គឺមាន RPART, NRPART, PILA, PILO, SUPPORT) ត្រូវបានសន្មតថា មានទំនាក់ទំនងជាមួយគ្នា។ ភាពអាចទុកចិត្តបាន (reliability) និងសុពលភាព (validity) នៃអញ្ញាតអរូបិយ ក៏ត្រូវបានត្រួតពិនិត្យដែរ។ ជំហានទី២ ក្នុង SEM គឺ ការធ្វើតេស្តបញ្ជាក់លើសម្មតិកម្មស្តីពី ទំនាក់ទំនងជាប្រព័ន្ធរវាងអញ្ញាតអរូបិយទាំង ៥។ ម៉ូដែលទំនាក់ទំនងជាប្រព័ន្ធ (structural model) វាប្រហាក់ប្រហែលគ្នានឹង ordinary least squares regression ដែរ។ ទំនាក់ទំនងណាមិនមានសារៈសំខាន់ គឺត្រូវដកចេញពីម៉ូដែល ហើយសម្មតិកម្មជាប់ពាក់ព័ន្ធនឹងវាក៏ត្រូវទាត់ចោលដែរ។ កម្មវិធីកុំព្យូទ័រសម្រាប់វិភាគ Mplus version 6.12 ដោយប្រើ maximum likelihood with robust standard error (MLR) estimator ត្រូវបានយកមកប្រើ ក្នុងជំហានទាំង ២។ MLR នេះ គេតែងផ្តល់មតិឲ្យយកមកប្រើសម្រាប់ ទិន្នន័យមិនមាន normality distribution និង មានសំណាកទំហំតូច។

## លទ្ធផល និងការពិភាក្សា

### ឥទ្ធិពលនៃការចូលរួមដោយមានកម្រៃ

ការវិភាគ ផ្តល់លទ្ធផលថា ការចូលរួមដោយមានកម្រៃ ជះឥទ្ធិពលវិជ្ជមានខ្លាំងទៅលើ ការចូលរួមដោយគ្មានកម្រៃ ដូចបានចែងក្នុងសម្មតិកម្ម។ ពិតហើយ អ្នកស្រុកដែលមានការចូលរួមដោយមានកម្រៃ តែងត្រូវមានការចូលរួមដោយគ្មានកម្រៃផងដែរ ដូចជាក្នុងការប្រជុំការបណ្តុះបណ្តាល និងសកម្មភាពអភិរក្សផ្សេងៗ។ តាមនេះ ការចូលរួមដោយមានកម្រៃ ដើរតួនាទីសំខាន់ក្នុងការជំរុញអ្នកស្រុកឲ្យចូលរួមក្នុងការអភិវឌ្ឍ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ដូចមានពិភាក្សានៅខាងដើម ការចូលរួមដោយមានកម្រៃជាទូទៅគេប្រើវាជាគ្រឿងលើកទឹកចិត្តឲ្យ អ្នកស្រុកជួយគាំទ្រដល់គម្រោង អេកូទេសចរណ៍ផ្អែកលើសហគមន៍។

លទ្ធផលបង្ហាញច្បាស់ថា ការចូលរួមដោយមានកម្រៃមានចំណែកតិចតួចណាស់ ក្នុងការជំរុញឲ្យអ្នកស្រុកមានទស្សនៈវិជ្ជមានពីផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយជួយគាំទ្រវា។ ការវិភាគផ្តល់គំនិតថា អ្នកស្រុកគ្រប់គ្នា ទោះមានការចូលរួមដោយមានកម្រៃកម្រិតណាក្តី គឺតែងមានទស្សនៈល្អពី ផលប៉ះពាល់នៃអេកូទេសចរណ៍ផ្អែកលើសហគមន៍ និងជួយគាំទ្រវាក្នុងកម្រិតប្រហែលគ្នា។ ចំណុចនេះអាចមានន័យថា ទស្សនៈល្អរបស់អ្នកស្រុកពីផលប៉ះពាល់នៃ អេកូទេសចរណ៍

ផ្អែកលើសហគមន៍ និងការជួយគាំទ្រវា ទំនងទទួលឥទ្ធិពលខ្លាំងជាងពីកត្តាផ្សេងទៀត ដូចជា បំណងចង់បានការអភិវឌ្ឍសេដ្ឋកិច្ចបន្ថែម ជាដើម (Campbell 1999; Lepp 2007)។ អាចមានហេតុផលមួយទៀតថា អ្នកស្រុកមានការចូលរួមដោយមានកម្រៃកម្រិតទាប តែមានឥរិយាបថវិជ្ជមាន និងការគាំទ្រខ្លាំងដល់ការអភិវឌ្ឍទេសចរណ៍ ដោយសារគាត់ជឿជាក់លើឥទ្ធិពលដោយប្រយោល (trickle-down effects) នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ពោលគឺ គាត់អាចយល់ឃើញថា អេកូទេសចរណ៍ផ្អែកលើសហគមន៍ ជួយលើកស្ទួយដោយផ្ទាល់នូវជីវភាពរបស់អ្នកស្រុកមួយក្រុម ដូច្នេះ វានឹងជួយកែលំអដោយប្រយោលតាមបែបបទណាមួយនូវជីវភាពរបស់អ្នកស្រុកឯទៀតដែរ។

## ឥទ្ធិពលនៃការចូលរួមដោយគ្មានកម្រៃ

ស្រដៀងគ្នានឹងការចូលរួមដោយមានកម្រៃដែរ លទ្ធផលវិភាគបង្ហាញថា ការចូលរួមដោយគ្មានកម្រៃមិនមានតួនាទីអ្វីគួរឲ្យកត់សំគាល់ទេ ក្នុងការបង្កើនទស្សនៈវិជ្ជមានលើការអភិវឌ្ឍទេសចរណ៍។ លទ្ធផលនេះស្រដៀងគ្នានឹងការសិក្សាដែល Nicholas, Thapa and Ko (2009) បានរាយការណ៍ឡើងថា ការចូលរួមរបស់សហគមន៍ មិនមានទំនាក់ទំនងអ្វីគួរឲ្យកត់សំគាល់ទេ ជាមួយនឹងទស្សនៈស្តីពីទេសចរណ៍មានចីរភាព។ ប៉ុន្តែការចូលរួមដោយគ្មានកម្រៃ មានទំនាក់ទំនងដោយផ្ទាល់ និងវិជ្ជមាន ជាមួយនឹង ការគាំទ្រ។ វាជាទំនាក់ទំនងខ្សោយក៏ពិតមែន ប៉ុន្តែអាចជួយគាំទ្រដល់ Lankford (1994) ដែលអះអាងថា បើសិនអ្នកស្រុកដឹងថា មានការគិតគូរដល់មតិយោបល់ និងផលប្រយោជន៍របស់គាត់នោះ គាត់កាន់តែទំនងជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ ការអះអាងនេះស្របគ្នានឹង ការរកឃើញរបស់ Lee (2013) ដែរ។ ផ្អែកលើលទ្ធផលទាំងនេះ គេអាចសន្និដ្ឋានថា អ្នកស្រុកដែលបានចូលរួមក្នុងការបណ្តុះបណ្តាលរបស់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ឬបានបញ្ចេញមតិក្នុងការប្រជុំពី អេកូទេសចរណ៍ផ្អែកលើសហគមន៍ តែងជួយគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ក្នុងកម្រិតខ្ពស់ជាង អ្នកមិនមានការចូលរួមដោយគ្មានកម្រៃ ពីព្រោះឆ្លងតាមការចូលរួមដោយគ្មានកម្រៃ អ្នកស្រុកអាចមានព័ត៌មានច្បាស់ជាង និងបានដឹងពីបំណងល្អ ស្ថានភាពពិត និងផលប្រយោជន៍នៃគម្រោងអេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយតាមនេះ អាចកាន់តែមានការយោគយល់ និងជឿទុកចិត្តលើ អេកូទេសចរណ៍ផ្អែកលើសហគមន៍ និងផលប៉ះពាល់របស់វា។

លទ្ធផលរកឃើញផ្តល់គំនិតទៀតថា អ្នកស្រុកដែលបានចូលរួមដោយមានកម្រៃ និងចូលរួមដោយគ្មានកម្រៃ តែងមានទស្សនៈវិជ្ជមានលើផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ និងការគាំទ្រដល់ទេសចរណ៍ប្រភេទនេះ ក្នុងកម្រិតខ្ពស់បន្តិចជាង អ្នកគ្រាន់តែបានចូលរួមដោយមានកម្រៃតែម្យ៉ាង។ ដូច្នេះគេអាចសន្និដ្ឋានបានថា ការចូលរួមដោយមានកម្រៃ គួបផ្សំនឹង ការចូលរួមដោយគ្មានកម្រៃ អាចជាវិធីសាស្ត្រមានប្រសិទ្ធភាពល្អ ដើម្បីទទួលបានការគាំទ្រពីអ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

លទ្ធផលរកឃើញបានបញ្ជាក់គាំទ្រដល់ មូលដ្ឋានគ្រឹះនៃទ្រឹស្តីនៃការដោះដូរគ្នាក្នុងសង្គម (social exchange theory) និងលទ្ធផលនៃការសិក្សាពីមុនៗ ពោលគឺ អ្នកស្រុកដែលជឿទុកចិត្តថា អេកូទេសចរណ៍ផ្អែកលើសហគមន៍ ជួយបង្កើនទ្រព្យទ្រង់ជីវភាព និងជួយលើកស្ទួយកម្រិតជីវភាព គឺច្រើនតែជួយគាំទ្រវា។

## សេចក្តីសន្និដ្ឋាន

លទ្ធផលរកឃើញបង្ហាញថា ការចូលរួមដោយមានកម្រៃមានតួនាទីគួរឲ្យកត់សំគាល់ ក្នុងការលើកទឹកចិត្តអ្នកស្រុកឲ្យចូលរួមក្នុងសកម្មភាពគ្មានកម្រៃនៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ទោះយ៉ាងនេះក្តី ការចូលរួមដោយមានកម្រៃមិនមានតួនាទីអ្វីសំខាន់ទេ ក្នុងការជំរុញឲ្យអ្នកស្រុកកាន់តែមានទស្សនៈល្អពីផលប៉ះពាល់ និងជួយគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ស្រដៀងគ្នាដែរ ការចូលរួមដោយគ្មានកម្រៃក្នុងអេកូទេសចរណ៍ផ្អែកលើសហគមន៍ មិនមានឥទ្ធិពលអ្វីគួរឲ្យកត់សំគាល់ទេទៅលើទស្សនៈពីផលប៉ះពាល់។ ប៉ុន្តែ ការចូលរួមដោយគ្មានកម្រៃជះឥទ្ធិពលវិជ្ជមាន ទៅលើការគាំទ្ររបស់អ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ម្យ៉ាងទៀត ការចូលរួមដោយមានកម្រៃ វាជះឥទ្ធិពលវិជ្ជមានដោយប្រយោលទៅលើការគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ឆ្លងតាមការចូលរួមដោយគ្មានកម្រៃ។ ចំណុចនេះផ្តល់គំនិតថា ការចូលរួមដោយមានកម្រៃ គួបផ្សំនឹង ការចូលរួមដោយគ្មានកម្រៃ គឺជាវិធីសាស្ត្រមានប្រសិទ្ធភាពល្អ ដើម្បីឲ្យមានការគាំទ្រពីអ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

## ឯកសារយោង


Campbell, Lisa M. 1999. "Ecotourism in Rural Developing Communities." *Annals of Tourism Research* 26 (3): 534–553.

Carter, R. W. (Bill), Thok Sokhom, Vicky O'Rourke and Tristan Pearce. 2015. "Sustainable Tourism and its Use as a Development Strategy in Cambodia: A Systematic Literature Review." *Journal of Sustainable Tourism* 23 (5): 797–818.

DFID (Department for International Development). 1999. "Sustainable Livelihoods Guidance Sheets." http://www.eldis.org/vfile/upload/1/document/0901/section2.pdf.

Lankford, Samuel V. 1994. "Attitudes and Perceptions Toward Tourism and Rural Regional Development." *Journal of Travel Research* 32 (3): 35–43.

Lee, T. H. 2013. "Influence Analysis of Community Resident Support for Sustainable Tourism Development." *Tourism Management* 34: 37–46.

Lepp, Andrew. 2007. "Residents' Attitudes Towards Tourism in Bigodi Village, Uganda." *Tourism Management* 28 (3): 876–885.


តទៅទំព័រ ១៤

Woosnam, Kyle M. 2012. "Using Emotional Solidarity to Explain Residents' Attitudes about Tourism and Tourism Development." *Journal of Travel Research* 51 (3): 315–327.

**Appendix: Structural Equation Modelling**

***Model specification***

Structural equation modelling (SEM) was used to explain the structural relationships between the factors of interest. Figure A1 illustrates the structural paths based on the hypotheses posited in the section on structural framework.

Figure A1: Theoretical model




RPART, NRPART, PILA, PILO and SUPPORT are latent variables, which were measured with respective sets of observed variables. RPART and NRPART are the self-reported frequencies of residents' remunerative and non-remunerative participation in CBET. The observed variables of PILA and PILO were created based on the Sustainable Livelihoods Guidance Sheet of the UK's Department for International Development (DFID 1999). Support for CBET was adopted from Woosnam's (2012) modified Tourism Impact Attitude Scale. The questions were rated on the seven-point Likert scale, where one designates never (for RPART and NRPART), extremely negative (for PILA and PILO) and strongly disagree (for SUPPORT), while seven represents extremely often (for RPART and NRPART), or extremely positive (for PILA and PILO) and strongly agree (for SUPPORT).

***Model selection***

Table A1 presents the model fit statistics for the measurement model, theoretical structural model and verified structural model.

***Measurement model***

Table A1 shows that the measurement model has a significant chi square ($\chi2$ = 202, df = 122, p-value < 0.001), suggesting that it was a poor fit for the data. However, chi square is likely to be significant when the sample is large, so it is recommended that researchers use alternative fit indices in addition to chi square. One of them is the ratio of $\chi2$/df, for which the cut-off value

Table A1: Model fit statistics

| Model Fit Index | Measurement Model | Structural Model | |
|---|---|---|---|
| | | Theoretical | Verified |
| **Absolute fit indices** | | | |
| Chi square | 201.64 | 201.64 | 204.42 |
| df | 122.00 | 122.00 | 125.00 |
| P-Value | 0.00 | 0.00 | 0.00 |
| $\chi^2$/df | 1.65 | 1.65 | 1.64 |
| CFA | 0.95 | 0.95 | 0.95 |
| TLI | 0.94 | 0.94 | 0.94 |
| SRMR | 0.05 | 0.05 | 0.05 |
| RMSEA | 0.06 | 0.06 | 0.06 |
| **Relative fit indices** | | | |
| **Satarro-Bentler chi square difference test** | | | |
| chi square difference (df=3) | | | 1.229 |
| p-value | | | 0.746 |

Source: Result of the authors' analysis, 2014

for a good fit model is < 3. The measurement model had a $\chi$2/df ratio of 1.65, indicating that the measurement model indeed had a good fit.

The comparative fit index (CFI) and Tucker-Lewis Index (TLI) were also used to examine the model fit. A model with CFI and TLI > 0.95 has a good fit. The measurement model had an acceptable fit because its CFI was 0.95 and TLI was 0.94. Moreover, standardised root mean square residual (SRMR) and root mean square error of approximation (RMSEA) were used to measure the misfit of the target model. The recommended cut-off values of SRMR and RMSEA are <0.05. The measurement model also had a good fit according to the misfit indices, with SRMR of 0.05 and RMSEA of 0.06. RMSEA was slightly higher than the cut-off value. Nonetheless, RMSEA < 0.08 is considered an acceptable fit.

The full CFA and measurement model results[1] cannot be shown here because of limited space. Based on the CFA results, all the latent variables had a high level of internal consistency because their composite reliability (CR) was greater than 0.70. They also had convergent validity because the standardised factor loadings of all the observed variables were statistically significant at the 1 percent level. Also, most standardised factor loadings were higher than 0.70, which is considered ideal. Only one standardised loading was less than 0.70 but higher than 0.50, and three of them were less than 0.50, but these observed variables were kept to retain the content validity of their latent variables.

***Theoretical structural model***

The theoretical structural model had the following fit indices: $\chi^2$/df = 1.65, CFI = 0.95, TLI = 0.94, SRMR = 0.05, RMSEA = 0.06. Hence, it had an acceptable fit, but several path coefficients were not statistically significant. The non-significant pathcoefficients were deleted to seek a simple model that fits the data well.

***Verified structural model***

The verified model also had a good fit ($\chi^2$/df = 1.64, CFI = 0.95, TLI = 0.94, SRMR = 0.05, RMSEA = 0.06). The Satorra-Bentler scaled chi square difference test was implemented to compare the theoretical model with the verified model. As presented in Table A1, Satarro-Bentler chi square difference was not significant, indicating that the verified model fits the sample data better than the theoretical model does. The verified model was selected as the final model.

**The results of analysis**

Figure A2 illustrates the structural paths of the verified model. The numbers in the parentheses are the statistically significant standardised coefficients of the direct effects. The statistically significant standardised coefficients of the indirect effects are shown in Table A2.

Figure A2: The verified model




Source: Result of the authors' analysis, 2014

Note: ( ) denotes standardised coefficients; significant at p-value <0.01*** and <0.05**.

1 The full CFA and measurement model results can be found in Ven (2017).

Table A2: Significant indirect effects

| H | Path | | | sc |
|---|---|---|---|---|
| | From | Via | To | |
| H11a | RPART | NRPART | PILO | 0.18** |
| H11b | RPART | NRPART | SUPPORT | 0.12** |
| H11c | RPART | NRPART PILO | SUPPORT | 0.06** |
| H13a | NRPART | PILO | SUPPORT | 0.07** |
| H13b | PILA | PILO | SUPPORT | 0.13** |

Source: Result of authors' analysis, 2014

Note: ** significant at p-value < 0.05.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៤ ឆ្នាំ២០១៦។

ផសស ពិត នៅឥណ្ឌូនេស៊ីមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៤,៩% ឬ ០,១ ឯកតាភាគរយ ទាបជាងក្នុងត្រីមាសទី៣ រីឯចំណាយរបស់រដ្ឋាភិបាលបានថយចុះ ៤,០%។ កំណើន ផសស នៅម៉ាឡេស៊ីឡើងដល់ ៤,៥% ធៀបនឹង ៤,៣% នៅត្រីមាសទី៣ ដោយសារចំណាយប្រើប្រាស់ឯកជន និងវិនិយោគជាទ្រព្យជាប់លាប់មានកំណើនខ្លាំង ដែលបានជួយប៉ះប៉ូវដល់ការថយចុះចំណាយប្រើប្រាស់របស់រដ្ឋាភិបាល។កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរី ឡើងដល់ ២,៩% ធៀបនឹង ១,១% ក្នុងត្រីមាសមុន រីឯវិស័យកម្មន្តសាលកើន ១១,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ សេដ្ឋកិច្ចថៃមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៣,០% ឬ ០,២ ឯកតាភាគរយ ទាបជាងក្នុងត្រីមាសមុន ដោយសារតម្រូវការក្នុងស្រុកកើនល្បឿន ហើយភាពមិនទៀងទាត់ក្នុងនយោបាយក៏មានស្ថិរភាពឡើង។ កំណើននៅវៀតណាមឡើងដល់ ៦,៧% ដោយសារវិស័យនាំចេញមានសន្ទុះខ្លាំង ទោះបីពាណិជ្ជកម្មក្នុងពិភពលោកថយល្បឿនក្តី។ វិស័យកម្មន្តសាលនៅវៀតណាមកើន ១៣,៦% នៅត្រីមាសទីនេះ ហើយវៀតណាមកំពុងក្លាយជាមជ្ឈមណ្ឌលមួយសម្រាប់ផលិតកម្មនៃផលិតផលអាឡិចត្រូនិក។

សេដ្ឋកិច្ចប្រទេសចិនមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៦,៨% ដែលជំរុញឡើងដោយសារ ចំណាយប្រើប្រាស់ឯកជននៅរឹងប៉ឹង ទោះបីវិនិយោគឯកជន និងតម្រូវការក្នុងពិភពលោកបានថយចុះក្តី។សេដ្ឋកិច្ចក្នុងតំបន់រដ្ឋបាលពិសេសក្រុងហុងកុងនៃប្រទេសចិនកើន៣,១%ធៀបនឹងកាលពីមួយឆ្នាំមុនគឺខ្ពស់ជាងក្នុងត្រីមាសមុនដែលមានត្រឹម ១,៣%។ កំណើននៅកូរ៉េខាងត្បូង នៅតែមិនសូវខ្លាំងបានត្រឹម ២,៣% គឺដូចគ្នានឹងត្រីមាសមុន ដោយសារចំណាយប្រើប្រាស់ឯកជន និងការនាំចេញ បានរួមចុះ។ ផសស នៅតៃវ៉ាន់ កើនដល់ ២,៩% ធៀបនឹងកាលពីមួយឆ្នាំមុន ដែលជាកំណើនខ្ពស់បំផុត គិតតាំងពីត្រីមាសទី២ ឆ្នាំ២០១៥ មក។

កំណើន ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំក្នុងតំបន់អឺរ៉ូ មានកម្រិត ១,៧% គឺស្មើគ្នានឹងត្រីមាសមុន។ សេដ្ឋកិច្ចជប៉ុនមានកំណើន ១,៦% ដែលជាកំណើនខ្ពស់បំផុត គិតតាំងពីត្រីមាសទី២ ឆ្នាំ២០១៤ មក ដោយសារ ចំណាយប្រើប្រាស់ឯកជនកើនល្បឿនបន្តិច ហើយវិនិយោគកើនឡើងយ៉ាងខ្លាំង។ នៅត្រីមាសនេះ សហរដ្ឋអាមេរិកមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ១,៩% ដោយសារវិនិយោគជាប់លាប់ និងចំណាយប្រើប្រាស់បានកើនឡើង។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ប្រទេសទាំងអស់ក្នុងអាស៊ាន និងនៅអាស៊ី មានអតិផរណាលើកលែងតែ សិង្ហបុរីដែលនៅទីនោះកម្រិតថ្លៃជាទូទៅគ្មានការប្រែប្រួល។ អតិផរណា មានកម្រិត ៣,៦% នៅកម្ពុជា ៣,៣% នៅឥណ្ឌូនេស៊ី ១,៧% នៅម៉ាឡេស៊ី ០,៧% នៅថៃ និង ៤,៤% នៅវៀតណាម។ វាមានកម្រិត ២,២% នៅចិន ១,២% នៅហុងកុង ១,៣% នៅកូរ៉េខាងត្បូង និង ១,៨% នៅតៃវ៉ាន់។ អតិផរណាមានដល់ ០,៧% នៅតំបន់អឺរ៉ូ ០,៣% នៅជប៉ុន និង ១,៩% នៅសហរដ្ឋអាមេរិក។

នៅត្រីមាសទី៤ ឆ្នាំ២០១៦ ប្រាក់រៀលឡើងថ្លៃ ១,៣% ទល់នឹងប្រាក់ដុល្លារ បើធៀបនឹងត្រីមាសមុន ដល់ ៤០៤១,៩រៀល/ដុល្លារ។ ប្រាក់បាតថៃចុះថ្លៃ ១,៧% ធៀបនឹងត្រីមាសមុន ដល់ ៣៥,៤បាត/ដុល្លារ ហើយប្រាក់ដុងវៀតណាមចុះថ្លៃ ០,៩% ដល់ ២២៤៩៣,៧ដុង/ដុល្លារ។ ធៀបនឹងត្រីមាសមុន ប្រាក់យ៉ន់ចិនចុះថ្លៃ ១,៩% ដល់ ៦,៨យ៉ន់/ដុល្លារ ហើយ ប្រាក់យ៉េនជប៉ុនចុះថ្លៃ ៦,៩% ដល់ ១០៩,៥យ៉េន/ដុល្លារ។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០១៦ ទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក បានឡើងថ្លៃ ធៀបនឹងត្រីមាសមុន លើកលែងតែផលិតផលមួយចំនួនតូច ដូចជា អង្ករ សណ្តែកសៀង និងពោតដែលបានចុះថ្លៃ។ អង្ករចុះថ្លៃ ១២,៦% ដល់ ៣៧៦,០ដុល្លារ/តោន, សណ្តែកសៀងចុះថ្លៃ ១,២% ដល់ ៤១១,៧ដុល្លារ/តោន ហើយ ពោតចុះថ្លៃ ០,៨% ដល់ ១៥២,២ដុល្លារ/តោន។ ប្រេងដូងប្រេងឡើងថ្លៃ ៤,៦% ដល់ ៧៥៣.០ដុល្លារ/តោន ហើយ កៅស៊ូឡើងថ្លៃ ២៧,២% ដល់ ១៧១៦,៩ដុល្លារ/តោន។ ប្រេងឆៅឡើងថ្លៃ ១០,៧% ដល់ ៤៧,៩ដុល្លារ/ធុង, សាំងឡើងថ្លៃ ៤,៦% ដល់ ០,៣៨៥ដុល្លារ/លីត្រ ហើយ ម៉ាសូតឡើងថ្លៃ ១០,៨% ដល់ ០,៤០២ដុល្លារ/លីត្រ។

អត្ថបទនេះ រៀបរាងដោយលោក វ៉ែន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

---

*តទៅទំព័រ ២១* **ឥទ្ធិពលនៃ...**

Nicholas, Lorraine N., Brijesh Thapa and Yong Jae Ko. 2009. “Residents’ Perspectives of a World Heritage Site: The Pitons Management Area, St. Lucia.” *Annals of Tourism Research* 36 (3): 390–412.

Pizam, Abraham. 1978. Tourism’s Impacts: The Social Costs of the Destination Community as Perceived by Its Residents. *Journal of Travel Research* 16, 4: 8–12.

Ven Seyhah. 2017. “Residents’ Attitude toward Community-Based Ecotourism in Cambodia: Based on Two Cases of Yeak Laom and Chi Phat Communes.” PhD Dissertation, Nagoya, Japan: Graduate School of International Development, Nagoya University. http://ir.nul.nagoya-u.ac.jp/jspui/bitstream/2237/26326/5/%E7%94%B211822%E4%B8%BB%E8%AB%96%E6%96%87.pdf.

Vesey, Catherine M., and Frederic Dimanche. 2000. "Urban Residents’ Perceptions of Tourism and Its Impacts." Unpublished manuscript, University of New Orleans, LA.

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១១-២០១៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.1 | 7.3 | 7.4 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.5 | 6.3 | 5.8 | 5.2 | 4.7 | 4.7 | 4.7 | 5.0 | 4.9 | 5.2 | 5.0 | 4.9 |
| ម៉ាឡេស៊ី | 4.9 | 5.4 | 4.6 | 6.0 | 5.6 | 4.9 | 4.7 | 4.5 | 4.2 | 4.0 | 4.3 | 4.5 |
| សិង្ហបុរី | 4.7 | 1.3 | 3.8 | 3.0 | 2.6 | 1.8 | 1.9 | 1.8 | 1.8 | 2.1 | 1.1 | 2.9 |
| ថៃ | 0.0 | 6.7 | 2.8 | 1.6 | 3.3 | 2.2 | 2.9 | 2.8 | 3.2 | 3.5 | 3.2 | 3.0 |
| វៀតណាម | 6.2 | 5.2 | 5.4 | 5.9 | 6.1 | 6.5 | 6.8 | 7.0 | 5.5 | 3.5 | 6.4 | 6.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.3 | 7.7 | 7.7 | 7.3 | 7.1 | 7.0 | 6.9 | 6.8 | 6.7 | 6.7 | 6.7 | 6.8 |
| ហុងកុង | 4.9 | 2.9 | 3.0 | 2.3 | 2.1 | 2.8 | 2.3 | 1.9 | 0.8 | 1.7 | 1.3 | 3.1 |
| កូរ៉េខាងត្បូង | 3.6 | 2.1 | 2.8 | 3.4 | 2.4 | 2.2 | 2.7 | 3.0 | 2.7 | 3.2 | 2.3 | 2.3 |
| តៃវ៉ាន់ | 4.2 | 1.2 | 2.2 | 3.5 | 3.4 | 0.5 | -1.0 | -0.5 | -0.8 | 0.7 | 2.0 | 2.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.6 | -0.5 | 0.1 | 0.7 | 1.0 | 1.2 | 1.6 | 1.5 | 1.5 | 1.6 | 1.7 | 1.7 |
| ជប៉ុន | -0.8 | 1.7 | 1.7 | 0.6 | -0.9 | 0.7 | 1.0 | 0.5 | 0.2 | 0.8 | 1.1 | 1.6 |
| សហរដ្ឋអាមេរិក | 1.8 | 2.1 | 1.8 | 2.4 | 2.7 | 2.3 | 2.2 | 1.8 | 2.1 | 1.2 | 1.3 | 1.9 |

Sources: International Monetary Fund, Economist and countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១១-២០១៦ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 5.5 | 3.0 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.4 | 3.1 | 3.0 | 3.6 |
| ឥណ្ឌូនេស៊ី | 5.4 | 4.3 | 7.0 | 6.4 | 6.6 | 7.1 | 7.1 | 4.8 | 4.3 | 3.5 | 3.0 | 3.3 |
| ម៉ាឡេស៊ី | 3.2 | 1.7 | 2.1 | 3.2 | 0.7 | 2.1 | 3.0 | 2.6 | 3.4 | 1.9 | 1.4 | 1.7 |
| សិង្ហបុរី | 5.2 | 4.6 | 2.3 | 1.0 | -0.3 | -0.4 | -0.6 | -0.7 | -0.8 | -0.9 | -1.5 | 0.0 |
| ថៃ | 3.8 | 3.0 | 2.2 | 1.9 | -0.5 | -1.1 | -1.1 | -0.9 | -0.5 | 0.3 | 0.3 | 0.7 |
| វៀតណាម | 18.6 | 9.3 | 6.6 | 4.8 | 0.7 | 1.0 | 0.5 | 0.3 | 1.3 | 2.2 | 2.8 | 4.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.4 | 2.7 | 2.6 | 2.0 | 1.2 | 1.4 | 1.7 | 1.5 | 2.1 | 2.1 | 1.7 | 2.2 |
| ហុងកុង | 5.3 | 4.1 | 4.0 | 4.4 | 4.4 | 3.1 | 2.3 | 2.4 | 2.9 | 2.6 | 3.1 | 1.2 |
| កូរ៉េខាងត្បូង | 4.4 | 2.1 | 1.1 | 1.3 | 0.6 | 0.5 | 0.6 | 1.1 | 0.2 | 0.9 | 0.8 | 1.3 |
| តៃវ៉ាន់ | 1.4 | 1.9 | 0.8 | 1.5 | 2.9 | -0.7 | 0.0 | 0.3 | 1.7 | 1.3 | 0.7 | 1.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.5 | 1.4 | 0.4 | -0.3 | 0.2 | 0.0 | 0.3 | 0.1 | 0.2 | 0.3 | 0.7 |
| ជប៉ុន | 0.1 | -0.03 | 0.4 | 2.8 | 2.3 | 0.5 | 0.2 | 0.7 | 0.2 | -0.4 | -0.5 | 0.3 |
| សហរដ្ឋអាមេរិក | 3.2 | 2.1 | 1.5 | 1.6 | -0.4 | 0.0 | 0.1 | 0.4 | 1.1 | 0.7 | 1.1 | 1.9 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១១-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4063.6 | 4037.8 | 4027.2 | 4037.6 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 | 4056.3 | 4094.1 | 4041.9 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8748.0 | 9363.0 | 10419.2 | 11850.2 | 12809.9 | 13125.2 | 13858.0 | 13786.3 | 13627.3 | 13324.1 | 13136.6 | 13265.3 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.1 | 3.1 | 3.3 | 3.6 | 3.7 | 4.1 | 4.3 | 4.2 | 4.0 | 4.0 | 4.3 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.2 | 1.3 | 1.3 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 30.5 | 31.1 | 30.7 | 32.5 | 32.6 | 33.2 | 35.2 | 35.8 | 35.6 | 35.3 | 34.8 | 35.4 |
| វៀតណាម (ដុង) | 20574.3 | 20856.9 | 20990.3 | 21138.2 | 21372.9 | 21712.7 | 22164.6 | 22420.7 | 22929.4 | 22314.5 | 22292.2 | 22493.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.5 | 6.3 | 6.1 | 6.2 | 6.2 | 6.2 | 6.3 | 6.4 | 6.5 | 6.5 | 6.7 | 6.8 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1108.6 | 1126.6 | 1095.0 | 1053.6 | 1101.7 | 1097.4 | 1170.0 | 1158.3 | 1200.8 | 1163.4 | 1120.9 | 1159.0 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 29.4 | 29.6 | 29.7 | 30.3 | 31.6 | 30.8 | 32.0 | 32.6 | 33.1 | 32.4 | 31.7 | 31.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 79.9 | 79.8 | 97.6 | 105.9 | 119.2 | 121.4 | 122.2 | 121.4 | 115.3 | 107.9 | 102.4 | 109.5 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១១-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No.2) - (USD/តោន) | 291.7 | 298.4 | 259.4 | 192.9 | 174.2 | 168.4 | 169.5 | 167.1 | 160.0 | 171.1 | 153.5 | 152.2 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (USD/តោន) | 1125.4 | 999.3 | 856.9 | 821.4 | 627.9 | 664.0 | 514.6 | 518.0 | 586.9 | 647.8 | 714.7 | 753.0 |
| កៅស៊ូ SMR 5 USD/តោន) | 4630.6 | 3200.7 | 2575.3 | 1755.6 | 1450.2 | 1525.9 | 1365.5 | 1229.1 | 1190.0 | 1408.1 | 1349.4 | 1716.9 |
| អង្ករ (Thai 100% B) - បាងកក (USD/តោន) | 558.5 | 594.8 | 533.8 | 434.9 | 426.0 | 396.3 | 383.3 | 376.3 | 385.3 | 465.0 | 430.3 | 376.0 |
| សណ្តែកសៀង (US No.1) - USA (USD/តោន) | 540.7 | 591.4 | 538.4 | 491.8 | 363.9 | 393.7 | 347.6 | 358.0 | 328.0 | 418.7 | 416.7 | 411.7 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 106.2 | 109.5 | 105.9 | 96.2 | 50.9 | 60.5 | 48.2 | 38.0 | 31.2 | 44.7 | 43.3 | 47.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 71.9 | 74.6 | 71.2 | 65.6 | 40.1 | 49.0 | 42.2 | 32.9 | 27.9 | 37.5 | 36.8 | 38.5 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 75.7 | 80.7 | 78.4 | 71.5 | 44.6 | 48.4 | 39.9 | 34.0 | 27.2 | 35.6 | 36.3 | 40.2 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០១៧ អនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុប បានរួមចុះអស់ ៤៦,៩% ដល់ ៥០៧,៤លានដុល្លារ ធៀបនឹង ៩៥៥,៥ លានដុល្លារ កាលពីត្រីមាសមុន។ ប៉ុន្តែធៀបនឹងកាលពីមួយឆ្នាំមុន វាបានកើនឡើង ០,៨%។ អនុម័តវិនិយោគខាងកសិកម្មកើន២០៦,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនដល់៨២,១ លានដុល្លារ។ អនុម័តវិនិយោគខាងឧស្សាហកម្មសរុប កើនដល់ ៣២០,៨ លានដុល្លារ ឬ ២០,៥% ខ្ពស់ជាងត្រីមាសមុន។ វិនិយោគក្នុងផ្នែកកាត់ដេរ មាន ១៩,០ លានដុល្លារ ឬត្រឹមតែ ៥,៩% នៃវិនិយោគខាងឧស្សាហកម្មសរុប។ អនុម័តវិនិយោគក្នុងផ្នែកសេវាកម្ម មាន ១០៤,៦ លានដុល្លារ ឬ ៨៤,៧% ទាបជាងកាលពីត្រីមាសមុន។វិនិយោគខាងសណ្ឋាគារនិងទេសចរណ៍មាន ៥៦,៣ លានដុល្លារ ឬធ្លាក់ចុះ ៩១,៧% ធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី៤ នេះដែរ ចំនួនទេសចរអន្តរជាតិមកដល់សរុបកើនដល់ប្រមាណ ១,៥ លាននាក់ គឺកើន ៤៧,៦% ធៀបនឹងត្រីមាសមុន ឬកើន ៥,២% ធៀបមួយឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១៧.០% ធៀបនឹងត្រីមាសមុន ដល់ប្រមាណ ៧៩៧.០០០ នាក់ រីឯភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក ថយចុះ ៥,៥% ដល់ប្រមាណ ៧០៥.០០០នាក់។

នៅត្រីមាសទី៤ ឆ្នាំ២០១៧ ការនាំចេញសរុប មាន ២.៤៥៤ លានដុល្លារ គឺកើន ១២,៩% ធៀបត្រីមាសមុន ឬកើន ៦,៣% ធៀបមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ មាន ១.៧៥៨,២ លានដុល្លារ ឬធ្លាក់ចុះ ១៥,២% ធៀបត្រីមាសមុន ប៉ុន្តែកើន ៤,៦% ធៀបមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក មាន ៤១៣,៥ លានដុល្លារ ទៅសហភាពអឺរ៉ុប មាន ៦២៩,២ លានដុល្លារ ទៅបណ្តាប្រទេសអាស៊ាន ២៥,៧ លានដុល្លារ ទៅជប៉ុន ១៤១,០ លានដុល្លារ និងទៅប្រទេសផ្សេងទៀត ៥៤៩,០ លានដុល្លារ។ ការនាំចេញផលិតផលកសិកម្ម កើន ៥២,០% ធៀបត្រីមាសមុន ឬកើន ១២,៤% ធៀបមួយឆ្នាំមុន ដល់ ១៧៩,៥ លានដុល្លារ ក្នុងនោះការនាំចេញកៅស៊ូ មាន ៥៩,៦ លានដុល្លារ, ការនាំចេញឈើ ១៨,៣ លានដុល្លារ, ការនាំចេញត្រី ០,២ លានដុល្លារ, ការនាំចេញអង្ករ ៩៩,៩ លានដុល្លារ, និងការនាំចេញផលិតផលកសិកម្មផ្សេងទៀត ១,៦ លានដុល្លារ។

នៅត្រីមាសទី៤ ដដែលនេះ ការនាំចូលសរុប កើន ២,១% ធៀបត្រីមាសមុន ឬកើន ៤,៥% ធៀបមួយឆ្នាំមុន ដល់ ៣.០៨០,៨ លានដុល្លារ។ ការនាំចូលសាំង មានដល់ ៩៧,១ លានដុល្លារ, ម៉ាស៊ូត មាន ១៧៨.០ លានដុល្លារ, សម្ភារសំណង់ ៥៧,៤ លានដុល្លារ, ការនាំចូលផ្សេងទៀត ២.៧៤៨,៤ លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១៦ ចំណូលរដ្ឋាភិបាលសរុប ធ្លាក់ចុះ ០,៣% ធៀបត្រីមាសមុន ដល់ ៣.៤០៥.០ ប៊ីលានរៀល ប៉ុន្តែកើន ១៨,៨% ធៀបមួយឆ្នាំមុន។ ចំណូលចរន្ត ធ្លាក់ចុះ ០,៤% ធៀបត្រីមាសមុន ដល់ ៣.៣៦១,៧ ប៊ីលានរៀល ចំណូលពន្ធ ធ្លាក់ចុះ ៤,៥% ដល់ ២.៧២២,៤ ប៊ីលានរៀល រីឯចំណូលមិនមែនពន្ធ កើន ២១,៧% ដល់ ៦៣៩,៤ ប៊ីលានរៀល។ ចំណូលមូលធន មានដល់ ៤៣,៣ ប៊ីលានរៀល។ ចំណាយសរុប កើន ២៩,០% ធៀបត្រីមាសមុន ដល់ ៤.៥០៩,២ ប៊ីលានរៀល ប៉ុន្តែធ្លាក់ចុះ ១២,០% ធៀបមួយឆ្នាំមុន។ ចំណាយមូលធន កើន ៤៤,៨% ធៀបត្រីមាសមុនដល់ ១.២២៥,៦ ប៊ីលានរៀល ហើយចំណាយចរន្ត កើន ២៤,០% ដល់ ៣.២៨៣,៦ ប៊ីលានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប មានដល់ ៣,៩% ឬ កើន ០,៩ ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៦% ប៉ុន្តែ

---
អត្ថបទនេះ រៀបរៀងដោយលោក វ៉ើន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

ថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៣,៤%។ ធៀបនឹងត្រីមាសមុន ប្រាក់រៀល ឡើងថ្លៃ ១,៣% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៤១,៩៖/ដុល្លារ, ឡើងថ្លៃ ២,៧% ទល់នឹងប្រាក់បាតថៃ ដល់ ១១៤,៩៖/បាត និង ឡើងថ្លៃ ២% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៨,១៖/១០០ ដុង។ ក្នុងពេលជាមួយគ្នា មាសចុះថ្លៃ ៥,៦% ដល់ ១៤៨,៣ ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ២,៦% ដល់ ៣.១២៩,៣៖/លីត្រ រីឯសាំងឡើងថ្លៃ ៤,៧% ដល់ ៣.៤៣៧,១៖/លីត្រ។

## ស្ថានភាពក្រីក្រ

នៅខែកុម្ភៈ ២០១៧ ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករត់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករត់ម៉ូតូឌុប ថយចុះ ធៀបនឹងកាលពីមួយឆ្នាំមុន រីឯចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នកលីសែង អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ កើនឡើង។

នៅខែកុម្ភៈ ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ១,៨% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ៨.៣៣២៖/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៦៧% ជាអ្នករកចំណូលចម្បងសម្រាប់គ្រួសារខ្លួន ហើយ ៤៧,៥% ប្រាប់ថា ចំណូលរបស់គាត់ចុះទាបជាងត្រីមាសមុន។ ពលករភាគច្រើនបញ្ជាក់ថា ចំណូលរបស់គាត់ក្នុងខែកុម្ភៈ អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។ ពលករប្រមាណ ៤៧% មានជាប់បំណុលគេ ហើយអត្រាការប្រាក់ជាមធ្យមលើការខ្ចីបុលនោះ គឺ ៣,២% ក្នុងមួយខែ។

ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើនឡើង ០,០១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៤.៨៨៩៖។ កម្មករ ប្រមាណ ៦១% រៀបការរួច។ ពួកគាត់មានកម្រិតអប់រំជាមធ្យមត្រឹមថ្នាក់ទី៦។ ជាមធ្យម កម្មករទាំងនេះធ្វើការឲ្យរោងចក្របាន ៤ឆ្នាំហើយ។ កម្មករប្រមាណ ៦១%ទទួលបានជំនាញពីការបណ្តុះបណ្តាលក្នុងរោងចក្រ ១១,៦%ពីការបណ្តុះបណ្តាលនៅផ្ទះ ហើយ ២៦,៦%ផ្សេងទៀតមិនមានជំនាញទេ។ ជាមធ្យម គាត់ធ្វើការ ៥៣,៨ ម៉ោង/សប្តាហ៍ និងសន្សំប្រាក់បានដល់ ៥១,៣% នៃប្រាក់កម្រៃរបស់ខ្លួន។ កម្មករប្រមាណ ៩៣% ផ្ញើប្រាក់សន្សំទៅឲ្យក្រុមគ្រួសារ ហើយអាចជួយទ្រទ្រង់ជីវភាពគ្រួសារបានមួយភាគ។ កម្មករប្រមាណ ៣៤,១% មិនចង់ផ្លាស់ប្តូរការងារទេ ប៉ុន្តែមាន ២៩,១% ចង់ផ្លាស់ប្តូរការងារ ហើយ ៣៦,៦% ទៀតមិនទាន់ច្បាស់ក្នុងចិត្ត។ កម្មករប្រមាណ ៥០% មានសុទិដ្ឋិនិយមថា រោងចក្រគាត់នៅតែមានដំណើរការតទៅមុខទៀត។

នៅខែកុម្ភៈ ចំណូលរបស់អ្នកលក់បន្លែតូចតាច ថយចុះ ៩,៥% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៨.៤១១៖/ថ្ងៃ។ អ្នកទាំងនេះមកពី ខេត្តកណ្តាល(៣០,០%) ស្វាយរៀង(២២,៥%) ព្រៃវែង(១៧,៥%) កំពង់ស្ពឺ(១៥,០%) តាកែវ(១០.០%) និងក្រុងភ្នំពេញ(៥,០%)។ ពួកគាត់ប្រមាណ ៨០% មានដីកសិកម្មពី ០,២ ទៅ ២,០ ហិកតា ហើយ ២០% គ្មានដីធ្លីទេ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយមាន ៥២% រាយការណ៍ថា មិនមានមូលធនគ្រប់គ្រាន់សម្រាប់បម្រើអាជីវកម្មរបស់ខ្លួនទេ។

ចំណូលរបស់អ្នករើសអេតចាយ កើន ២,៩% ធៀបនឹងកាលពីមួយឆ្នាំមុនដល់១១.៤៧៨៖/ថ្ងៃ។ពួកគាត់ភាគច្រើនប្រាប់ថា ចំនួនអ្នករើសអេតចាយកើនឡើង ហើយ ប្រភពសម្រាម និងថ្លៃរបស់អេតចាយ បានថយចុះ ធៀបនឹងកាលពីបីខែមុន។ អ្នកឆ្លើយសម្ភាសន៍ប្រមាណ ៩២% ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ហើយត្រូវធ្វើការជាមធ្យម ១១,២ ម៉ោង/ថ្ងៃ។ ពួកគាត់ចំណាយភាគច្រើនទៅលើ ស្បៀងអាហារ(៧១,៦% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៥,៧%) ការថែទាំសុខភាព(២,៥%) និង ចំណាយផ្សេងទៀត(១០,១%)។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ កើន ៣,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៦.៦៦៤៖ ហើយ ចំនួនរបស់ពួកគាត់ និងសកម្មភាពសាងសង់ បានកើនឡើង។ កម្មករ ៨៥% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ។ ជាមធ្យម ពួកគាត់ធ្វើការ ៩,៣ ម៉ោង/ថ្ងៃ។ ចំណូលរបស់ពួកគាត់ ត្រូវចាយវាយទៅលើស្បៀងអាហារ(៧៤% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៣,៤%) ការថែទាំសុខភាព(០,២%) និងចំណាយផ្សេងទៀត(១២,៥%)។ ចំណូលរបស់ពួកគាត់ អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

ចំណូលរបស់អ្នកលីសែង កើន ១,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ១៥.១៧១៖/ថ្ងៃ។ អ្នកលីសែង ៨៥% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ។ ចំណូលរបស់ពួកគាត់ ត្រូវចាយវាយទៅលើស្បៀងអាហារ(៧៦,១% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៥,៨%) ការថែទាំសុខភាព(១,២%) និងចំណាយផ្សេងទៀត(៦,៨%)។ អ្នកឆ្លើយសម្ភាសន៍ ៦០% ប្រាប់ថា តាំងពីចាប់ផ្តើមធ្វើជាអ្នកលីសែងមក គ្រួសាររបស់គាត់មានជីវភាពប្រសើរជាងមុន ហើយ ៣៧,៥% ប្រាប់ថាគ្រួសារគាត់មានជីវភាពនៅដដែល រីឯ ២,៥% ទៀតប្រាប់ថា មានជីវភាពខ្វះខាតជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន ធ្លាក់ចុះ ០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៧.៩០៥៖។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ទទួលបានកន្លែងស្នាក់នៅពីម្ចាស់ហាង។ ពួកគាត់ធ្វើការនេះបានប្រហែល ៣ ឆ្នាំមកហើយ និងត្រូវបម្រើការក្នុងហាងជាមធ្យម ១១,៤ ម៉ោង/ថ្ងៃ។ ពួកគាត់ចំណាយប្រាក់ចំណូលរបស់ខ្លួនអស់ ៧៧,២% លើស្បៀងអាហារ ៥,៤% លើការថែទាំសុខភាព និង ១៧,៤% លើចំណាយផ្សេងៗទៀត។

# តាមដានសេដ្ឋកិច្ច - សូចនាករសេដ្ឋកិច្ច

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១១-១៦*

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 725.0 | 531.6 | 930.5 | 56.5 | 25.8 | 38.1 | 79.1 | 26.8 | 27.6 | 0.0 | 7.4 | 82.1 |
| ឧស្សាហកម្ម | 2860.1 | 829.3 | 3257.0 | 1002.5 | 342.8 | 130.9 | 130.6 | 410.4 | 252.4 | 597.0 | 266.1 | 320.8 |
| *កាត់ដេរ* | 393.9 | 497.0 | 324.1 | 393.5 | 63.9 | 42.4 | 63.7 | 55.2 | 70.8 | 239.9 | 51.1 | 19.0 |
| សេវាកម្ម | 3425.4 | 916.6 | 140.7 | 622.6 | 2504.6 | 85.6 | 69.7 | 74.5 | 643.6 | 234.1 | 681.9 | 104.6 |
| *សណ្ឋាគារ និងទេសចរណ៍* | 2850.9 | 691.5 | 106.0 | 446.9 | 60.6 | 0.0 | 0.0 | 38.0 | 611.1 | 19.8 | 679.8 | 56.3 |
| សរុប | 7010.4 | 2278.0 | 4328.0 | 1583.9 | 2873.2 | 254.6 | 279.4 | 511.7 | 923.7 | 831.2 | 955.5 | 507.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 1816.8 | -91.1 | 9.7 | 83.1 | 80.5 | -10.0 | 15.0 | -46.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 209.0 | -67.5 | 90.1 | 63.4 | 573.0 | -33.2 | -55.3 | 241.4 | -67.9 | 226.4 | 242.0 | -0.8 |

*Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១១-១៦

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1480.4 | 1722.1 | 2017.7 | 2273.5 | 725.1 | 497.4 | 563.8 | 681.3 | 785.0 | 593.5 | 602.2 | 797.4 |
| តាមផ្លូវគោក និងទឹក | 1401.4 | 1862.2 | 2192.5 | 2229.3 | 647.6 | 496.7 | 481.1 | 747.0 | 557.4 | 522,7 | 545,3 | 705.9 |
| សរុប | 2881.8 | 3584.3 | 4210.2 | 4502.8 | 1372.6 | 994.2 | 1044.9 | 1428.4 | 1342.5 | 1116.2 | 1147.5 | 1503.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 5.4 | -27.6 | 5.1 | 36.7 | -0.6 | -16.9 | 2.8 | 47.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 20.1 | 24.4 | 17.5 | 7.0 | 8.3 | 6.5 | 4.6 | 9.6 | -2.4 | 12.3 | 9.8 | 5.2 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១១-១៦ *

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 4929.5 | 6106.4 | 6982.4 | 8106.0 | 2170.1 | 2182.0 | 2595.0 | 2309.3 | 2388.3 | 2383.4 | 2817.7 | 2454.0 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 4259.6 | 5015.4 | 5386.1 | 5960.5 | 1548.8 | 1601.7 | 1995.3 | 1681.2 | 1759.4 | 1717.8 | 2072.5 | 1758.2 |
| - សហរដ្ឋអាមេរិក | 2055.3 | 2143.3 | 2075.2 | 1963.6 | 491.1 | 494.3 | 585.3 | 438.8 | 423.1 | 440.4 | 554.5 | 413.5 |
| - សហភាពអឺរ៉ុប | 1322.2 | 1716.9 | 1969.6 | 2403.7 | 617.3 | 685.9 | 844.1 | 756.6 | 789.6 | 776.6 | 733.4 | 629.2 |
| - អាស៊ាន | 17.6 | 39.4 | 60.2 | 83.3 | 24.8 | 24.6 | 26.4 | 27.5 | 25.6 | 25.7 | 21.4 | 25.7 |
| - ជប៉ុន | 147.0 | 188.6 | 278.7 | 383.1 | 121.4 | 93.6 | 170.8 | 138.4 | 176.0 | 122.5 | 216.0 | 140.9 |
| - ប្រទេសផ្សេងៗ | 717.5 | 927.2 | 1002.9 | 1126.8 | 294.2 | 303.4 | 368.8 | 319.9 | 345.2 | 352.7 | 547.1 | 548.9 |
| កសិកម្ម | 362.1 | 376.7 | 554.5 | 624.4 | 150.3 | 127.3 | 111.4 | 159.7 | 137.5 | 98.9 | 118.1 | 179.5 |
| - កៅស៊ូ | 197.6 | 176.6 | 175.2 | 153.9 | 41.7 | 40.9 | 42.1 | 40.7 | 30.7 | 26.8 | 48.3 | 59.6 |
| - ឈើ | 48.8 | 36.8 | 73.6 | 132.0 | 13.9 | 9.8 | 7.3 | 15.3 | 4.9 | 12.4 | 11.6 | 18.3 |
| - ត្រី | 3.1 | 2.0 | 1.2 | 0.8 | 0.2 | 0.2 | 0.1 | 0.1 | 0.2 | 0.1 | 0.2 | 0.2 |
| - អង្ករ | 106.6 | 146.4 | 262.3 | 248.5 | 89.5 | 72.4 | 54.7 | 98.8 | 91.4 | 56.1 | 53.4 | 99.9 |
| - ផលិតផលកសិកម្មផ្សេងៗ | 6.0 | 14.9 | 42.4 | 89.1 | 5.2 | 4.0 | 7.2 | 4.9 | 10.3 | 3.6 | 4.6 | 1.6 |
| ផ្សេងៗ | 307.9 | 714.4 | 1088.2 | 1520.1 | 471.0 | 452.9 | 488.0 | 468.4 | 491.3 | 566.6 | 627.1 | 516.2 |
| ការនាំចូលសរុប ក្នុងនេះ៖ | 6375.9 | 8593.3 | 8639.4 | 10295.4 | 2717.3 | 2920.3 | 2907.9 | 2949.1 | 2784.7 | 6136.6 | 3017.0 | 3080.8 |
| សាំង | 294.4 | 308.0 | 306.4 | 334.7 | 34.5 | 92.2 | 96.5 | 65.1 | 95.4 | 99.2 | 93.3 | 97.1 |
| ម៉ាស៊ូត | 447.0 | 559.5 | 569.1 | 602.3 | 45.1 | 152.7 | 139.6 | 150.0 | 163.1 | 194.6 | 173.7 | 178.0 |
| សម្ភារសំណង់ | 48.1 | 66.1 | 80.8 | 117.6 | 12.4 | 42.0 | 45.9 | 42.1 | 50.8 | 62.1 | 83.1 | 57.4 |
| ផ្សេងៗ | 5586.4 | 7659.1 | 7682.6 | 9240.7 | 835.2 | 2633.0 | 2626.0 | 2691.9 | 2475.0 | 5780.8 | 2667.0 | 2748.4 |
| ជញ្ជីងពាណិជ្ជកម្ម | -1446.4 | -1341.6 | -1610.9 | -2184.3 | -547.2 | -738.3 | -312.9 | -639.7 | -390.7 | -3753.3 | -199.4 | -626.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | 3.8 | 3.4 | 24.6 | -15.7 | 4.7 | -2.4 | 20,6 | -15.2 |
| ការនាំចេញសរុប | - | - | - | - | 1.5 | 0.5 | 18.9 | -11.0 | 3.4 | -0.2 | 18,2 | -12.9 |
| ការនាំចូលសរុប | - | - | - | - | -3.2 | 7.5 | -0.4 | 1.4 | -5.6 | 120.8 | -50,8 | 2.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 32.1 | 17.7 | 7.4 | 10.7 | 5.8 | 16.1 | 22.8 | 12.6 | 13.6 | 7.2 | 3.9 | 4.6 |
| ការនាំចេញសរុប | 35.8 | 23.9 | 14.3 | 16.1 | 9.8 | 17.3 | 21.7 | 8.1 | 10.1 | 9.2 | 8.6 | 6.3 |
| ការនាំចូលសរុប | 22.8 | 16.8 | 15.4 | 19.7 | 21.4 | 19.2 | 4.0 | 5.0 | 2.5 | 110.1 | 110.1 | 3.8 |

* Including tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១១-១៦ (ប៊ីលានរៀល)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 6251.4 | 7691.9 | 8255.2 | 10,543.4 | 2647.8 | 3301.6 | 3063.8 | 2867.3 | 3533.1 | 3849.7 | 3413.7 | 3405.0 |
| ចំណូលចរន្ត | 6179.3 | 7443.8 | 8233.2 | 10359.4 | 2638.0 | 3274.5 | 3028.7 | 2818.2 | 3514.7 | 3836.3 | 3375.9 | 3361.7 |
| ចំណូលពន្ធ | 5277.5 | 6334.8 | 7198.1 | 8995.2 | 2430.6 | 3006.1 | 2656.2 | 2409.7 | 3255.5 | 3368.1 | 2850.5 | 2722.4 |
| ពន្ធក្នុងស្រុក | 4071.6 | 5002.8 | 5728.1 | 7226.5 | 2012.6 | 2481.6 | 2153.9 | 1943.6 | 2715.3 | 2854.5 | 2378.5 | 2237.4 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1205.9 | 1331.7 | 1470.0 | 1822.7 | 418.0 | 524.5 | 502.3 | 466.1 | 540.1 | 513.6 | 472.0 | 485.0 |
| ចំណូលមិនមែនពន្ធ | 901.8 | 1118.2 | 1035.2 | 1310.3 | 207.4 | 268.5 | 372.5 | 408.5 | 259.3 | 468.2 | 525.4 | 639.4 |
| ចំណូលលើទ្រព្យសម្បត្តិ | 63.8 | 143.0 | 84.0 | 88.5 | 3.0 | 16.7 | 35.9 | 21.7 | 8.1 | 26.1 | 43.2 | 38.5 |
| លក់ទំនិញ និងសេវា | 588.7 | 667.4 | 750.3 | 871.2 | 189.6 | 219.2 | 304.6 | 333.9 | 198.5 | 315.3 | 294.9 | 439.5 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 249.3 | 298.8 | 200.8 | 350.5 | 14.8 | 32.6 | 31.8 | 53.0 | 52.7 | 126.8 | 187.3 | 161.3 |
| ចំណូលជាមូលធន | 72.1 | 247.9 | 73.4 | 184.0 | 9.8 | 27.1 | 35.0 | 49.1 | 18.3 | 13.4 | 38.4 | 43.3 |
| ចំណាយសរុប | 9032.4 | 9660.9 | 12535.7 | 13306.5 | 2093.3 | 1964.8 | 3337.5 | 5121.3 | 2364.3 | 3405.3 | 3460.8 | 4509.2 |
| ចំណាយជាមូលធន | 3546.9 | 3628.3 | 5567.5 | 5590.7 | 654.4 | 584.7 | 649.9 | 2083.4 | 620.9 | 1091.1 | 811.3 | 1225.6 |
| ចំណាយចរន្ត | 5341.2 | 6188.4 | 6968.3 | 7715.8 | 1438.9 | 1380.1 | 2687.7 | 3038.0 | 1743.4 | 2314.2 | 2649.1 | 3283.6 |
| បៀវត្សរ៍ | 2170.6 | 2486.6 | 2997.3 | 3755.5 | 945.3 | 959.1 | 1281.2 | 1086.3 | 1133.1 | 1418.3 | 1403.6 | 1426.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1518.8 | 1586.8 | 1563.0 | 1627.0 | 194.3 | 207.1 | 544.0 | 797.1 | 259.1 | 439.7 | 447.5 | 628.7 |
| ចំណាយចរន្តផ្សេងទៀត | 1651.8 | 2115.1 | 2408.0 | 2333.4 | 299.3 | 213.9 | 862.4 | 1154.6 | 351.2 | 456.2 | 798.1 | 1228.2 |
| សមតុល្យជាទូទៅ | -1271.4 | -1969.0 | -4280.6 | -2763.1 | 554.5 | 1336.8 | -273.8 | -2254.0 | 1168.8 | 444.4 | -47.0 | -1104.2 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -2781.0 | 2457.8 | 4326.2 | 3972.1 | 368.9 | 330.1 | 297.6 | 1414.8 | 266.4 | 775.6 | 141.0 | 661.9 |
| ហិរញ្ញប្បទានក្នុងស្រុក | 2379.2 | -332.9 | 824.4 | -1428.7 | -2464.8 | -793.3 | -259.1 | -109.4 | -1631.4 | -488.5 | 37.5 | 342.7 |

Source: MEF website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០១១-១៦

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.4 | 2.3 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.5 | 3.0 | 3.0 | 3.9 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 6.5 | 2.5 | 3.9 | 4.9 | 4.2 | 3.9 | 3.3 | 4.7 | 4.7 | 6.2 | 5.5 | 6.0 |
| - ដឹកជញ្ជូន | 6.9 | 3.3 | -0.6 | -1.0 | -10.9 | -7.9 | -9.1 | -8.9 | -6.5 | -9.9 | -7.9 | -3.4 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4063.6 | 4039.2 | 4036.2 | 4060.4 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 | 4056.3 | 4094.1 | 4041.9 |
| រៀលក្នុង ១ បាតថៃ | 133.2 | 130.0 | 124.9 | 119.4 | 124.4 | 122.6 | 116.8 | 113.6 | 113.4 | 115.7 | 118.1 | 114.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.7 | 19.4 | 19.1 | 18.7 | 19.0 | 18.8 | 18.6 | 18.2 | 18.1 | 18.3 | 18.5 | 18.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 184.5 | 200.9 | 175.9 | 152.3 | 150.9 | 144.4 | 136.0 | 130.9 | 151.2 | 151.2 | 157.1 | 148.3 |
| ថ្លៃម៉ាស៊ូត (រ/លីត្រ) | 4761.2 | 4941.2 | 4852.1 | 4934.1 | 3823.4 | 4032.0 | 3840.2 | 3389.4 | 2903.8 | 2932.8 | 3050.2 | 3129.3 |
| ថ្លៃសាំង (រ/លីត្រ) | 5044.5 | 5312.7 | 5083.3 | 5155.7 | 3986.2 | 4189.0 | 4048.9 | 3582.5 | 3310.6 | 3318.2 | 3281.4 | 3437.1 |

Sources: NIS, NBC and CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១១-១៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 17893.9 | 18154.5 | 21260.1 | 26699.7 | 26823.0 | 27975.3 | 26359.2 | 26665.5 | 29247.8 | 30138.5 | 32188.4 | 32814.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 5760.8 | 10437.4 | 11508.3 | 15859.8 | 16863.2 | 18178.3 | 20600.9 | 22157.6 | 21643.0 | 24399.1 | 24939.2 | 25802.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2123.1 | -2486.4 | -2794.9 | -4359.1 | -5064.0 | -5666.1 | -5933.1 | -6428.8 | -7621.2 | -7977.4 | -7916.6 | -8148.5 |
| ឥណទានដល់វិស័យឯកជន | 17552.8 | 23536.6 | 27608.8 | 36244.6 | 37759.4 | 40995.0 | 43807.1 | 46071.0 | 47627.0 | 52528.6 | 54551.1 | 56458.8 |
| រូបិយវត្ថុទូទៅ M2 | 23654.7 | 28591.9 | 32768.4 | 42559.5 | 43685.2 | 46153.7 | 46960.1 | 48823.1 | 50890.9 | 54537.6 | 57127.5 | 57616.8 |
| រូបិយវត្ថុ M1 | 3956.2 | 4045.7 | 4878.2 | 6308.4 | 6628.0 | 6293.1 | 6287.5 | 6741.4 | 6717.8 | 6872.0 | 7460.9 | 7273.0 |
| រូបិយវត្ថុផ្សេងៗ | - | - | - | - | 37058.2 | 39860.6 | 40672.6 | 42081.7 | 44173.1 | 47665.6 | 49666.6 | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 17.8 | 20.9 | 14.6 | 29.9 | 24.2 | 20.6 | 15.2 | 14.7 | 16.5 | 18.2 | 21.7 | 18.0 |
| រូបិយវត្ថុ M1 | 16.9 | 2.3 | 20.6 | 29.3 | 23.3 | 20.3 | 12.6 | 6.9 | 1.4 | 9.2 | 18.7 | 7.9 |
| រូបិយវត្ថុផ្សេងៗ | 17.9 | 44.6 | 13.6 | 30.0 | 24.4 | 20.7 | 15.6 | 16.1 | 19.2 | 19.6 | 22.1 | 19.6 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | 2016 | | |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា** | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នករត់ស៊ីក្លូ | 10303 | 10438 | 10774 | 12405 | 11880 | 11898 | 11302 | 10985 | 11092 | 1.9 | -44 | -6.6 |
| អ្នកលីសែង | 12143 | 13247 | 13580 | 15631 | 14888 | 11774 | 14094 | 13514 | 15171 | 4.7 | -4.7 | 1.9 |
| អ្នកលក់បន្លែតូចតាច | 10771 | 11366 | 14751 | 15867 | 20337 | 18979 | 11903 | 17488 | 18411 | -5.7 | 6.1 | -9.5 |
| អ្នករើសអេតចាយ | 8680 | 9819 | 9173 | 12344 | 11159 | 8737 | 9953 | 11347 | 11478 | -13.5 | 0.1 | 2.9 |
| អ្នករត់តុភោជនីយដ្ឋាន* | 6111 | 6697 | 7789 | 8436 | 7860 | 8187 | 7895 | 8015 | 7905 | 3.6 | 3.6 | 0.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 6599 | 7514 | 8745 | 8484 | 7916 | 7722 | 8229 | 8332 | -16.8 | -7.5 | -1.8 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10161 | 11178 | - | 14937 | 13828 | 12900 | 13136 | 14889 | -11.6 | -10.9 | 0.01 |
| អ្នករត់ម៉ូតូឌុប | 12930 | 13450 | 13386 | 14455 | 15526 | 15425 | 13653 | 13434 | 14770 | 2.8 | -6.7 | -4.9 |
| កម្មករសំណង់គ្មានជំនាញ | 11078 | 13184 | 13336 | 15349 | 16164 | 20227 | 13894 | 19174 | 16664 | 6.2 | 31.1 | 3.1 |
| កម្មករសំណង់មានជំនាញ | 13743 | 15442 | 17420 | 18624 | 18853 | 21150 | 19184 | 20287 | 21716 | 7.9 | 13.8 | 15.2 |

* Waitresses/waiters' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. **November 2015 data are not available, so percentage changes in November 2016 were estimated.

Source: CDRI

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

CDRI និង ចាក់ផ្សាយដោយស្ថានីយទូរទស្សន៍ SEA TV។

២ មីនា ២០១៧ ភ្នំពេញ

**សន្និសីទថ្នាក់ជាតិស្ដីពី "ការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃសម្រាប់ឧស្សាហូបនីយកម្មកំណើន និងការអភិវឌ្ឍ ក្នុងសម័យឌីជីថល"**។ សន្និសីទកម្រិតខ្ពស់ប្រចាំឆ្នាំនេះ ជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI នឹងធនាគារ ANZ រ៉ូយ៉ាល់។ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថាគន្លឹះបើក សន្និសីទដែលមានអ្នកចូលរួមប្រមាណ ៤០០ នាក់។ បទបង្ហាញដោយក្រុមវាគ្មិនទាំងបី ផ្ដោតលើបទពិសោធន៍មានជោគជ័យក្នុងតំបន់, ការបន្សីគោលនយោបាយជាមួយនឹង សកម្មភាពនិងតម្រូវការរបស់សហគ្រាស, និង ការកសាងមូលធនមនុស្ស សម្រាប់ទំនើបកម្មខ្សែសង្វាក់បង្កើតតម្លៃ។ ឯកសារផ្សេងៗនៃសន្និសីទ និង អត្ថបទសង្ខេបសម្រាប់សន្និសីទថ្នាក់ជាតិ មានចុះនៅលើគេហទំព័ររបស់ CDRI។

៣ មីនា ២០១៧ ភ្នំពេញ

**កិច្ចប្រជុំក្រុមប្រឹក្សាភិបាល CDRI រង្វាន់លទ្ធផលវិសេសឆ្នាំ២០១៦ និងការអបអរសាទរទិវានារី**។ ឯកឧត្តមបណ្ឌិត សុខ ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាល CDRI បានលើកសរសើរលោកនាយកប្រតិបត្តិ និង អ្នកគ្រប់គ្រងជាន់ខ្ពស់ លើការដឹកនាំដ៏រឹងប៉ឹងប្រកបដោយប្រសិទ្ធភាព និងបានអរគុណដល់បុគ្គលិកទាំងអស់ដែលបានខិតខំធ្វើការយ៉ាងខ្លាំងក្លា។ រង្វាន់ប្រាំសម្រាប់លទ្ធផលវិសេស បានប្រគល់ជូនដល់ បុគ្គល និងក្រុមនានា ក្នុងពេលពិសារអាហារថ្ងៃត្រង់រួមគ្នារវាង ក្រុមប្រឹក្សាភិបាល និងបុគ្គលិក CDRI ដើម្បីអបអរសាទរ ទិវានារីផងដែរ។

១៥ មីនា ២០១៧ ភ្នំពេញ

**ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាង CDRI នឹង SDC**។ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ CDRI ដើម្បីផ្ដល់មូលនិធិបន្ថែមចំនួន ៥០ម៉ឺនដុល្លារ សម្រាប់គម្រោងរយៈពេល ៣,៥ឆ្នាំ ស្ដីពី "ការស្រាវជ្រាវ និងកិច្ចសន្ទនាផ្នែកគោលនយោបាយលើ TVET"។

២៤ មីនា ២០១៧ ភ្នំពេញ

**វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍**(គំនិតបែបថ្មី)។ លោកនាយកប្រតិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់រៀបចំឡើងដោយ ក្រុមប្រឹក្សាជាតិស្ដីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងផែនការ លើ សេចក្ដីព្រាងឯកសារក្របខ័ណ្ឌសម្រាប់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

២០-២២ មីនា ២០១៧ នៅក្រុង Shenzhen ប្រទេសចិន

**CDRI និង Southern University of Science and Technology (SUSTech) បានចុះហត្ថលេខាលើ អនុស្សរណៈព្រមព្រៀង**។ លោកនាយកប្រតិបត្តិ និង អ្នកស្រាវជ្រាវផ្នែកអប់រំ ៣នាក់ បានធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យ SUSTech នៅក្រុង Shenzhen ប្រទេសចិន ដើម្បីចុះហត្ថលេខាលើ អនុស្សរណៈព្រមព្រៀង ជាមួយនឹង មជ្ឈមណ្ឌលអន្តរជាតិសម្រាប់នវានុវត្តន៍(គំនិតបែបថ្មី)នៅថ្នាក់ឧត្តមសិក្សា (មជ្ឈមណ្ឌលប្រភេទ២ របស់អង្គការយូណេស្កូ)។ ក្នុងនោះ មានគម្រោងសហការស្រាវជ្រាវជាច្រើនទៅអនាគតលើ គំនិតផ្ដួចផ្ដើមខ្សែក្រវាត់មួយ ផ្លូវមួយ។ គណៈប្រតិភូ ក៏បានទៅទស្សនា សាលាពហុបច្ចេកទេសនៅក្រុង Shenzhen ដើម្បីស្វែងរកកិច្ចសហការក្នុងការស្រាវជ្រាវពី TVET។ សាលាពហុបច្ចេកទេសបានអញ្ជើញ CDRI ទៅចូលរួមក្នុង វេទិកា TVET សកល នៅខែមិថុនា ២០១៧។ លោកនាយកប្រតិបត្តិក៏បានអញ្ជើញសាស្ត្រាចារ្យម្នាក់ឲ្យចូលរួមក្នុង គណៈកម្មាធិការវិទ្យាសាស្ត្រ នៃសមាគមការអប់រំប្រៀបធៀប នៃសន្និសីទអាស៊ី ដែលនឹងធ្វើឡើងនៅខេត្តសៀមរាប ក្នុងខែឧសភា ២០១៨។

២៨ មីនា ២០១៧ ភ្នំពេញ

**CDRI និង សាលាសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ (IDEC) នៃសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា បានចុះហត្ថលេខាលើអនុស្សរណៈព្រមព្រៀង**។ អនុស្សរណៈព្រមព្រៀងនេះមាន ៣ចំណែកគឺ កិច្ចសហការស្រាវជ្រាវលើគោលនយោបាយផ្នែកឧត្តមសិក្សា ការផ្លាស់ប្ដូរអ្នកស្រាវជ្រាវ និង សន្និសីទថ្នាក់ជាតិនិងអន្តរជាតិរួមគ្នាផ្សេងៗ។

## ការស្រាវជ្រាវ

### *ផ្នែកកសិកម្ម*

ក្រុមស្រាវជ្រាវផ្នែកនេះ កំពុងអនុវត្ត ៥គម្រោង។ របាយការណ៍សម្រាប់គម្រោងស្ដីពី *ផលប៉ះពាល់នៃ គោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង* កំពុងលូតលាស់ទៅមុខយ៉ាងរលូន។ ការជួយមតិផ្សេងៗលើរបាយការណ៍សម្រេចសម្រាប់ការសិក្សាស្ដីពី *កសិកម្មស្រោចស្រពនៅកម្ពុជា* ដែលទទួលបានជំនួយគាំទ្រពីសាកលវិទ្យាល័យជាតិអូស្ត្រាលី (ANU) ក្រុមស្រាវជ្រាវបានទទួលយក និងកំពុងដោះស្រាយ រីឯចំណែកណាមានខ្លឹមសារសព្វគ្រប់ហើយ កំពុងធ្វើការកែសម្រួលផ្នែកភាសា។ ក្រុមស្រាវជ្រាវ កំពុងរៀបចំប្រមូលទិន្នន័យចុងក្រោយសម្រាប់គម្រោងស្ដីពី *ការសាកល្បងប្រើគំរូបែបថ្មីនៃការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ក្នុងគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE)* ដែលទទួលមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI)។ របាយការណ៍សម្រេចស្ដីពី *ការវិភាគលើគោលនយោបាយស្រូវ* ដែលទទួលមូលនិធិពី គំនិតផ្ដួចផ្ដើមផ្នែកគោលនយោបាយសាធារណៈនៅតំបន់មេគង្គក្រោម (LMPPI) បានបញ្ជូនទៅ LMPPI ដើម្បីទទួលបានមតិយោបល់ផ្សេងៗ។ គម្រោងចុងក្រោយស្ដីពី *ការនាំចេញផលិតផលកសិកម្មទៅតំបន់មេគង្គ មានជាអាទិ៍ ថៃ វៀតណាម និង ចិន* ត្រូវបានអនុវត្តឡើងក្រោមកិច្ចសហការជាដៃគូរវាង CDRI និង SIDA ពីឆ្នាំ២០១៦ ដល់ ២០២១។ បន្ទាប់ពីការសិក្សាលើឯកសារមានស្រាប់ ក្រុមស្រាវជ្រាវកំពុងរៀបចំឯកសារគោលគំនិតសម្រាប់សិក្ខាសាលាពិគ្រោះយោបល់មួយនាពេលខាងមុខ។

### ផ្នែកសេដ្ឋកិច្ច

ការសិក្សាពី *ទំនាក់ទំនងរវាង គោលនយោបាយសាធារណៈនៃប្រទេសជាដៃគូ ចំណាកស្រុក និងអភិវឌ្ឍន៍៖ ករណីសិក្សា និងការផ្តល់មតិផ្នែកគោលនយោបាយ* បានចប់សព្វគ្រប់ប្រកបដោយជោគជ័យ។ វិទ្យាស្ថាន CDRI និង អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ នឹងរៀបចំពិធីផ្សព្វផ្សាយសៀវភៅមួយនៅថ្ងៃទី២៧ មេសា នៅក្រុងភ្នំពេញ។ គម្រោងស្តីពី *ការស្រាវជ្រាវពីវិធានការមិនមែនពន្ធគយ សម្រាប់អនុវត្តលើការនាំចេញផលផលរបស់កម្ពុជា* ក៏ជិតបានរួចរាល់ដែរ។ ក្រុមស្រាវជ្រាវបានធ្វើរបាយការណ៍ជូនម្ចាស់ជំនួយ និងគ្រោងលើកបង្ហាញពីលទ្ធផលរកឃើញជាដំបូងៗនៅក្នុងកិច្ចសន្ទនានៃបណ្តាញអាស៊ី-ប៉ាស៊ីហ្វិកនៃការស្រាវជ្រាវនិងបណ្តុះបណ្តាលពី ពាណិជ្ជកម្ម (ARTNeT) ស្តីពី *ការវិភាគលើវិធានការមិនមែនពន្ធគយ៖ ការប្រមូលភស្តុតាង និង កំណត់របៀបវារៈស្រាវជ្រាវ* នៅថ្ងៃទី ២៦-២៧ មេសា នៅក្រុងបាងកក ប្រទេសថៃ។

បានជឿនលឿនទៅមុខល្អដែរ គឺកម្មវិធីរយៈពេល ៣ឆ្នាំ ស្តីពី *ការកែលំអលទ្ធភាពមានការងារធ្វើសម្រាប់ជនវ័យក្មេង៖ ទីផ្សារពលកម្ម ការអភិវឌ្ឍជំនាញ និងការអភិវឌ្ឍវិស័យឯកជន ក្នុងតំបន់មេគង្គធំទូលាយ ក្នុងក្របខ័ណ្ឌនៃ បណ្តាញស្រាវជ្រាវនៅមហាអនុតំបន់មេគង្គ (GMS-Net)* ដែលជាសម្ព័ន្ធស្រាវជ្រាវថ្នាក់តំបន់មួយសម្របសម្រួលដោយ CDRI និងទទួលបានមូលនិធិពី មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានអន្តរជាតិនៃប្រទេសកាណាដា (IDRC)។ ក្រុមស្រាវជ្រាវនៃប្រទេសនីមួយៗ ត្រូវប្រគល់របាយការណ៍សម្រេចរបស់ខ្លួននៅខែឧសភា និងលើកបង្ហាញពីលទ្ធផលស្រាវជ្រាវឃើញក្នុងសិក្ខាសាលាបច្ចេកទេសថ្នាក់តំបន់មួយ នៅពេលក្រោយមកទៀត។

មានគម្រោង ៣ទៀត បានជឿនលឿនទៅមុខដូចគ្នា។ គម្រោងទី១គឺ *វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងការវិវត្តនៃទីផ្សារពលកម្ម៖ ការសិក្សាពិសោធន៍ដោយចៃដន្យ ក្នុងចំណោមយុវជនពេញវ័យកម្ពុជា* ដែលទទួលបានមូលនិធិពី GMS-Net។ ក្រុមស្រាវជ្រាវបានបង្ហើយអង្កេតគោល និងតាមដានបន្ត ហើយបច្ចុប្បន្ន កំពុងរៀបចំរបាយការណ៍សម្រេចដែលត្រូវធ្វើចេញនៅខែឧសភា។ ទី២ គឺគម្រោងស្តីពី *ការបង្ហាញជាក់ស្តែងពីការចូលរួមរបស់កម្ពុជានៅក្នុងខ្សែសង្វាក់តម្លៃសកល (GVCs)*, ដែលជា ការសិក្សាស្រាវជ្រាវក្នុងក្របខ័ណ្ឌនៃ កម្មវិធីស្រាវជ្រាវរយៈពេល ៥ឆ្នាំផ្តល់មូលនិធិដោយ Sida ស្តីពី *ការអភិវឌ្ឍឧស្សាហកម្ម មូលធនមនុស្ស និង ការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម (SME) នៅកម្ពុជា*។ ក្រុមស្រាវជ្រាវ បានបង្ហើយការសិក្សាឯកសារស្រាវជ្រាវមានស្រាប់ ហើយបច្ចុប្បន្នកំពុងពិនិត្យមូលដ្ឋានទិន្នន័យ GVC មុនពេលចាប់ផ្តើមការចុះសិក្សាដល់កន្លែង។ គំរោងទី៣គឺ *ការលើកកម្ពស់ការស្រាវជ្រាវចិន-មេគង្គ និង កិច្ចសន្ទនាផ្នែកគោលនយោបាយ* ដែលទទួលបានមូលនិធិពីក្រសួងការបរទេសចិន ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការ និងកិច្ចសន្ទនា Lancang-ទន្លេមេគង្គ បានលូតលាស់ទៅមុខយឺតៗ។ ការរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោង ត្រូវពន្យាពេលរហូតដល់មានការជូនដំណឹងបន្ថែម។

ការងារបានចាប់ផ្តើមលើគម្រោងស្តីពី *គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់កម្ពុជា និងខ្សែក្រវាត់មួយ ផ្លូវមួយ (OBOR)—ការអភិវឌ្ឍខេត្តព្រះសីហនុ ទៅជា តំបន់សេដ្ឋកិច្ចពិសេសមានទិសដៅច្រើន និង ការប្រើប្រាស់គំនិតផ្តួចផ្តើម OBOR* ដែលផ្តល់មូលនិធិដោយមជ្ឈមណ្ឌលស្រាវជ្រាវផ្លូវសូត្រសមុទ្រសតវត្សទី២១ របស់កម្ពុជា។ បច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងសិក្សាលើឯកសារស្រាវជ្រាវមានស្រាប់ ហើយគ្រោងចុះសិក្សាដល់កន្លែងនៅខែមិថុនា។

### ផ្នែកអប់រំ

ការប្រមូលទិន្នន័យសម្រាប់គម្រោងស្តីពី *ការសិក្សាពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) សម្រាប់ទីផ្សារពលកម្ម* និងគម្រោងស្តីពី *អន្តរជាតូបនីយកម្មនៃឧត្តមសិក្សា និងការស្រាវជ្រាវ* កំពុងដំណើរការយ៉ាងល្អ ហើយអង្កេតសម្រាប់គម្រោងទី១បានរួចរាល់ជាស្រេច។ ក្រុមស្រាវជ្រាវក្នុងផ្នែកនេះកំពុងជួយគាំទ្រដល់ស្ថាប័នឧត្តមសិក្សាក្នុងការកសាង សេចក្តីព្រាងច្បាប់មួយ សម្រាប់លើកស្ទួយអាជីពសិក្សាស្រាវជ្រាវនៅកម្ពុជា និងជួយគាំទ្រដល់ស្ថាប័ននីមួយៗក្នុងការលើកកម្ពស់ចំណាប់អារម្មណ៍ផ្នែកស្រាវជ្រាវ និងការកសាងសមត្ថភាពស្រាវជ្រាវ ក្នុងចំណោមក្រុមសាស្ត្រាចារ្យមហាវិទ្យាល័យ និងនិស្សិត។ ដោយឡែក កាលពីខែមីនា ក្រុមស្រាវជ្រាវបានធ្វើទស្សនកិច្ចនៅ សាកលវិទ្យាល័យជាស៊ីមកំចាយម៉ា ព្រៃវែង។ ដើម្បីជានាឲ្យការស្រាវជ្រាវ និងការផ្តល់មតិផ្នែកគោលនយោបាយមានភាពពាក់ព័ន្ធល្អ ក្រុមស្រាវជ្រាវគ្រោងធ្វើទស្សនកិច្ចជាទៀងទាត់នៅតាមស្ថាប័នឧត្តមសិក្សានានា ពិសេសនៅខាងក្រៅរាជធានី។

របាយការណ៍នៃការសិក្សាមួយ ធ្វើឡើងក្រោមកិច្ចសន្យាជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ស្តីពី *ស្ថានភាពបច្ចុប្បន្ន និងតម្រូវការផ្នែកឧស្សាហកម្មនូវអ្នកបច្ចេកទេសអគ្គិសនី* ក្នុងចំណោម ៥៧ក្រុមហ៊ុន និង ៣វិទ្យាស្ថាន ដែលផ្តល់នូវ TVET នៅក្រុងភ្នំពេញ បានចប់រួចរាល់ ដោយមានការផ្សព្វផ្សាយលទ្ធផល នៅក្នុងសិក្ខាសាលាមួយនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លទ្ធផលរកឃើញទទួលបានការគាំទ្រច្រើន ហើយស្របគ្នានឹង លទ្ធផលនៃការពិភាក្សាតាមក្រុមវាគ្មិន ដែលមានការចូលរួមពីអ្នកតំណាងមកពីវិស័យឯកជន អ្នកកសាងគោលនយោបាយ និងថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យមកពីវិទ្យាស្ថាន TVET ទាំង ៣។

នៅខែមីនា គណៈប្រតិភូ CDRI មួយ មានលោកនាយកប្រតិបត្តិ និងអ្នកស្រាវជ្រាវក្នុងផ្នែកអប់រំ ៣នាក់ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) មួយរវាងវិទ្យាស្ថាន CDRI នឹងមជ្ឈមណ្ឌលអន្តរជាតិនៃ យូណេស្កូ សម្រាប់នវានុវត្តន៍ក្នុងការអប់រំថ្នាក់ឧត្តមសិក្សា នៅឯសាកលវិទ្យាល័យ Southern University of Science and Technology នៅក្រុង Shenzhen ប្រទេសចិន។ គណៈប្រតិភូក៏បានធ្វើទស្សនកិច្ចនៅ សាលា Shenzhen Polytechnic ដើម្បីស្វែងរកកិច្ចសហការក្នុងការស្រាវជ្រាវផ្នែកគោលនយោបាយ TVET។

ផ្នែកអប់រំនេះ ដើរតួនាទីស្នូលក្នុងការកសាង MOU ២ ថែមទៀត គឺមួយធ្វើឡើងជាមួយ សាលាជាន់ខ្ពស់សម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ (Graduate School for International Development and Cooperation) នៃសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុន និង មួយទៀតជាមួយ សាកលវិទ្យាល័យ Charles Darwin ប្រទេសអូស្ត្រាលី។ ក្នុងភាពជាដៃគូទាំងពីរនេះ មានជា

អាទិ៍ គម្រោងស្រាវជ្រាវសហការគ្នា ជំនួយឥតសំណង និងការផ្លាស់ប្តូរសម្ភារសិក្សា និងអ្នកសិក្សាស្រាវជ្រាវ ហើយនិងសន្និសីទ និងសិក្ខាសាលាស្រាវជ្រាវ។

### *ផ្នែកបរិស្ថាន*

របាយការណ៍សម្រេច និងឯកសារសង្ខេបផ្នែក*គោលនយោបាយសម្រាប់គម្រោងស្តីពី បញ្ហាយេនឌ័រក្នុង ការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាននៅកម្ពុជា* ដែលផ្តល់មូលនិធិដោយ USAID ក្រោម ភាពជាដៃគូនៅតំបន់មេគង្គដើម្បីបរិស្ថាន បានចងក្រងរួចរាល់។ បានផ្សព្វផ្សាយហើយដែរ គឺ *ការសិក្សាសំយោគលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជីវភាពរស់នៅ និងកំណើនសម្រាប់គ្រប់គ្នា*។ ម្យ៉ាងទៀត អ្នកស្រាវជ្រាវក្នុងផ្នែកនេះបានចូលរួមជាមួយអ្នកស្រាវជ្រាវក្នុងផ្នែកអភិបាលកិច្ច អនុវត្តគម្រោងស្រាវជ្រាវចំនួន ២។ គម្រោងទី១ គឺ *MK20: លំហសម្រាប់កិច្ចសន្ទនា* ដែលផ្តោតលើ *បញ្ហាយេនឌ័រនិងដំណើរការតាំងលំនៅឡើងវិញ និង វេទិកាអ្នកពាក់ព័ន្ធផ្សេងៗជាមួយនឹងទំនប់វារីអគ្គិសនីសេសានក្រោម២*គ្រោងចប់សព្វគ្រប់នៅចុងឆ្នាំ២០១៧។ គម្រោងទី២ ស្តីពី *សេដ្ឋកិច្ចនយោបាយនៃសង្គមស៊ីវិល* ដែលទទួលបានមូលនិធិពី USAID កំពុងស្ថិតក្នុងដំណាក់កាលកំណត់គោលគំនិត និងធ្វើផែនការ ហើយការចុះសិក្សាដល់កន្លែងគ្រោងចាប់ផ្តើមនៅខែមិថុនា។ អ្នកស្រាវជ្រាវក្នុងផ្នែកបរិស្ថានក៏បានចូលរួមជាមួយវិទ្យាស្ថាន Stockholm Environment Institute ដើម្បីរៀបចំ និងដំណើរការកិច្ចប្រជុំថ្នាក់ជាតិមួយស្តីពី "ការស្រូបយកជាតិពុលអាសេនិកពីក្នុងស្រូវអង្ករនៅប្រទេសកម្ពុជា" នៅរាជធានីភ្នំពេញ នៅថ្ងៃទី២៣ កុម្ភៈ ២០១៧។

ផ្នែកនេះបានធ្វើសំណើស្រាវជ្រាវជាច្រើន ដើម្បីដាក់ជូនទៅដៃគូនានាដែលអាចជួយផ្តល់មូលនិធិក្នុងនោះមាន២សំណើកំពុងរង់ចាំការពិនិត្យ និងសម្រេចយល់ព្រមពី Forum Syd និង មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ។ ម្យ៉ាងទៀត ឯកសារគោលគំនិតសម្រាប់សំណើអនុវត្តគម្រោងស្តីពី *ការប្រើប្រព័ន្ធថាមពលព្រះអាទិត្យ ដើម្បីកែលំអការគ្រប់គ្រងទឹកក្នុងការដាំដុះស្រូវ*កំពុងទទួលការពិនិត្យពី មូលនិធិពិសេសនៃសហប្រតិបត្តិការ Lancang-ទន្លេមេគង្គ។ គម្រោងនេះសំដៅអនុវត្តសាកល្បងនូវប្រព័ន្ធបូមទឹកបម្រើកសិកម្ម ដើរដោយថាមពលព្រះអាទិត្យ រួមទាំងប្រឡាយ និង អាងស្តុកទឹក ដើម្បីស្រោចស្រពដីស្រែ យ៉ាងហោចណាស់ឲ្យបាន ៣០០ ហិកតា ហើយលុបបំបាត់បញ្ហាកង្វះទឹកនិងថាមពលដែលតែងកាត់បន្ថយផលិតភាពកសិកម្ម។

### *ផ្នែកអភិបាលកិច្ច*

ក្រុមស្រាវជ្រាវផ្នែកអភិបាលកិច្ច កំពុងធ្វើការសិក្សាជាច្រើននៅក្នុងគម្រោងរបស់ Sida *ស្តីពីមនុស្សជំនាន់ថ្មី និងក្នុងគម្រោងទឹកដីនិងប្រព័ន្ធអេកូឡូស៊ី (WLE) ស្តីពីអភិបាលកិច្ចទឹកទន្លេមេគង្គ*។ សៀវភៅស្តីពីមនុស្សជំនាន់ថ្មីរបស់កម្ពុជា បានរីកចម្រើនទៅមុខយ៉ាងល្អ ក្នុងនោះជំពូកនានាបានសរសេររួចរាល់ ហើយអ្នកចងក្រងសៀវភៅក៏បានត្រួតពិនិត្យស្រេចបាច់ដែរ។ សៀវភៅនេះ គ្រឹះស្ថានបោះពុម្ព NIAS Press នៅក្នុង វិទ្យាស្ថាន Nordic Institute of Asian Studies, University of Copenhagen, Denmark បានយល់ព្រមធ្វើការបោះពុម្ពផ្សាយឲ្យហើយ។ របាយការណ៍សិក្សាឯកសារស្រាវជ្រាវស្តីពីយុវជនកម្ពុជា ដែលត្រូវបោះពុម្ពផ្សាយ ជាឯកសារពិភាក្សារបស់ CDRI និងការរចនារៀបចំអង្កេតលើយុវជនកម្ពុជា បានជឿនលឿនទៅមុខ ហើយត្រូវរួចរាល់អស់ នៅត្រីមាសខាងមុខ។

ក្នុងឋានៈជាសមាជិកនៃក្រុមការងារភាពជាដៃគូសម្រាប់វិមជ្ឈការ បណ្ឌិត អេង នេត្រា បានធ្វើបទបង្ហាញស្តីពី "លទ្ធផលរកឃើញចម្បងៗ នៃការស្រាវជ្រាវរបស់ CDRI ស្តីពី កំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅកម្ពុជា" នៅក្នុងពេលប្រជុំសមាជិកប្រចាំត្រីមាស នៅរាជធានីភ្នំពេញ នៅថ្ងៃទី ២៤ កុម្ភៈ។ លោកស្រីក៏បានធ្វើបទបង្ហាញពី "និន្នាការក្នុងនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍" នៅក្នុង សន្និសីទប្រចាំឆ្នាំនៃសមាគមនៃការសិក្សាពីអាស៊ាន ក្នុងក្រុងToronto ពីថ្ងៃទី ១៦ ដល់ ១៩ មីនា។

ក្រុមស្រាវជ្រាវសម្រាប់គម្រោង *អភិបាលកិច្ចទឹកទន្លេមេគង្គ* កំពុងធ្វើការសិក្សាចម្បងៗពីរ ដើម្បីពិនិត្យពីការយល់ឃើញ និងបទពិសោធន៍នៃតួអង្គសំខាន់ៗដែលចូលរួមក្នុង វេទិកាអ្នកពាក់ព័ន្ធផ្សេងៗ និងផលប៉ះពាល់ផ្នែកយេនឌ័រនៃការធ្វើផែនការតាំងលំនៅឡើងវិញ និងប្រតិបត្តិការពាណិជ្ជកម្មនៃទំនប់វារីអគ្គិសនីសេសានក្រោម២។ ទិន្នន័យសម្រាប់ការសិក្សាទាំង២ បានប្រមូលយកតាមការចុះសិក្សាដល់កន្លែងជាច្រើន ក្នុងខេត្តស្ទឹងត្រែង កាលពីខែកុម្ភៈ និង មីនា។ ដោយរួមសហការជាមួយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ផ្នែកនេះកំពុងផលិតឯកសារវីដេអូមួយស្តីពី "អត្ថប្រយោជន៍ និងផលប៉ះពាល់ផ្នែកសង្គម និងអេកូឡូស៊ី នៃការកសាងទំនប់វារីអគ្គីសនី"។ អ្នកស្រាវជ្រាវ ឆំ ធារី និងជំនួយការស្រាវជ្រាវ ហាវ ហ្គិចហុង បានចូលរួមក្នុងវេទិកាអ្នកពាក់ព័ន្ធស្តីពីការសិក្សារបស់ក្រុមប្រឹក្សា និង គម្រោងកសាងទំនប់វារីអគ្គិសនីប៉ាក់បេង នៅក្រុងហ្លួងប្រាបាង ប្រទេសឡាវ កាលពីថ្ងៃទី២២-២៣ កុម្ភៈ និងសិក្ខាសាលាថ្នាក់ជាតិបន្ថែមទៀត នៅខេត្តសៀមរាប លើប្រធានបទដដែល។

### *ផ្នែកសុខាភិបាល*

ក្រុមស្រាវជ្រាវផ្នែកសុខាភិបាល កំពុងអនុវត្តគម្រោងស្រាវជ្រាវមួយស្តីពី *ក្រមវិជ្ជាជីវគ្រូពេទ្យនៅកម្ពុជា៖ បញ្ហាចោទ និងផ្លូវឈានទៅមុខ*។ គម្រោងនេះទទួលបាន មូលនិធិពីក្រុមហ៊ុន GlaxoSmithCline (GSK) ដោយមានកិច្ចសហការជាដៃគូពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS)។ គម្រោងនេះមានគោលដៅពីរគឺ ទាក់ទាញសាធារណជនឲ្យយកចិត្តទុកដាក់ពីបញ្ហាផ្នែកសុខាភិបាលនៅកម្ពុជា និងរំលឹកដល់និស្សិតពេទ្យ និងអ្នកអនុវត្តការងារសុខាភិបាល ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការគាំពារសុខភាពរបស់ប្រជាជន។ ឯកសារព្រាងទាក់ទងនឹងគោលគំនិតស្តីពីក្រមវិជ្ជាជីវៈគ្រូពេទ្យ និងសំណើសម្រាប់ធ្វើការស្រាវជ្រាវ ដោយផ្អែកលើឯកសារវិទ្យាសាស្ត្រ និងរបាយការណ៍មានស្រាប់ ត្រូវបានរៀបចំឡើង។ ឥឡូវនេះ ក្រុមស្រាវជ្រាវកំពុងរៀបចំវិធីសាស្ត្រស្រាវជ្រាវដោយផ្តោតជាសំខាន់ទៅលើ លក្ខណៈសម្បត្តិរបស់គ្រូពេទ្យល្អ។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

១២ មករា ២០១៧ ភ្នំពេញ

**គណៈប្រតិភូ CDRI បានជួបសម្តែងការគួរសមជាមួយ ឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា។** គណៈប្រតិភូអ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI (លោក ឈឹម ឈុន លោក កែវ បូរិន លោក ហ៊ីង វុត្ថា និង បណ្ឌិត យៀង សុធី) ដឹកនាំដោយ បណ្ឌិត ឆែម រិទ្ធី នាយកប្រតិបត្តិ និង បណ្ឌិត ចែម ផល្លា នាយកស្រាវជ្រាវស្តីទី បានទៅជួបសម្តែងការគួរសមជាមួយ ឯកឧត្តមបណ្ឌិត Xiong Bo ឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសចិនប្រចាំនៅកម្ពុជា។ ក្នុងជំនួបនេះ គណៈប្រតិភូបានរៀបរាប់ពីសកម្មភាពស្រាវជ្រាវផ្នែកគោលនយោបាយរបស់ CDRI ជាពិសេស គម្រោងជាប់ទាក់ទងនឹងគំនិតផ្តួចផ្តើមរបស់ប្រទេសចិនស្តីពី "ខ្សែក្រវាត់មួយ ផ្លូវមួយ"។ តាមសំណើរបស់ CDRI ស្ថានទូតចិនបានយល់ព្រមជាគោលការណ៍ផ្តល់មូលនិធិសម្រាប់ការបង្កើត មជ្ឈមណ្ឌលធនធានសិក្សាស្រាវជ្រាវពីប្រទេសចិននៅក្នុង CDRI។

២៦ មករា ២០១៧ ភ្នំពេញ

**សិក្ខាសាលាថ្នាក់តំបន់ស្តីពី "សន្តិសុខតាមសមុទ្រនៅតំបន់អាស៊ីប៉ាស៊ីហ្វិកៈ ប្រវត្តិសាស្ត្រ បញ្ហាប្រឈម និងដំណោះស្រាយ"។** ព្រឹត្តិការណ៍កម្រិតខ្ពស់នេះ វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាជាយុទ្ធសាស្ត្រ បានរៀបចំឡើងទាន់ពេលល្អណាស់ ដោយបានផ្តល់ជា វេទិកាសម្រាប់ការបង្កើនសហប្រតិបត្តិការផ្ទៃក្នុងតំបន់លើបញ្ហាសន្តិសុខតាមសមុទ្រ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការគំរាមកំហែងប្លែកៗពីមុនដល់សន្តិសុខ ដូចជា ការរេចរឹលបរិស្ថាន ជំងឺរាតត្បាត ចំណាកស្រុកមិនទៀងទាត់ ក៏មានលើកមកពិភាក្សាដែរ។ នាយកប្រតិបត្តិនៃ CDRI បានធ្វើជាអ្នកសម្របសម្រួល ក្នុងវគ្គពិភាក្សាមួយ។

១៦ កុម្ភៈ ២០១៧ ភ្នំពេញ

**បណ្ឌិតសភា Neeson Cripps (NCA) បានបើកដំណើរការនៅតំបន់ស្ទឹងមានជ័យ ដោយនាំមកនូវ ការអប់រំបច្ចេកទេសមានគុណភាពកម្រិតសាកល។** NCA គឺជាកន្លែងអប់រំនិងបណ្តុះបណ្តាលទំនើបបំផុត ដែលសាងសង់ឡើងសម្រាប់ អង្គការមូលនិធិកុមារកម្ពុជា (CCF)។ ដោយមាន មន្ទីរពិសោធន៍វិទ្យាសាស្ត្រតាមស្តង់ដាអន្តរជាតិ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូផងនោះ NCA បានជួយឲ្យ ការអប់រំផ្នែក STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា) ឡើងដល់កម្រិតថ្មីមួយទៀតនៅកម្ពុជា។ ការជួបជុំគ្នាជាផ្លូវការនេះ ជាឱកាសល្អវិសេសមួយសម្រាប់ឲ្យ លោកនាយកប្រតិបត្តិធ្វើទំនាក់ទំនងជាមួយ អ្នកកសាងគោលនយោបាយលើ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដៃគូអភិវឌ្ឍន៍ គ្រូបង្រៀន និងយុវជននៅតំបន់ស្ទឹងមានជ័យ។

២០ កុម្ភៈ ២០១៧ ភ្នំពេញ

**វេជ្ជសាស្ត្រពីចម្ងាយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។** លោកនាយកប្រតិបត្តិបានចូលរួមក្នុងសិក្ខាសាលាមួយ ស្តីពី វេជ្ជសាស្ត្រពីចម្ងាយ (Telemedicine: ការផ្តល់សេវាថែទាំសុខភាពដល់អ្នកជំងឺនៅតាមតំបន់ដាច់ស្រយាល ដោយប្រើបច្ចេកវិទ្យាទូរគមនាគមន៍) និងបានជួបទាក់ទងជាមួយ អ្នកកសាងគោលនយោបាយមកពីក្រសួងសុខាភិបាល និងអ្នកតំណាងមកពីសាលាពេទ្យនានា និងមកពីបណ្តាក្រុមហ៊ុនវេជ្ជសាស្ត្រពីចម្ងាយនៅប្រទេសចិន។ ទីស្តីការគណៈរដ្ឋមន្ត្រីបានរៀបចំសិក្ខាសាលានេះឡើង ដើម្បីបង្កើនការយល់ដឹងពីប្រយោជន៍សំខាន់នៃវេជ្ជសាស្ត្រពីចម្ងាយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

២២ កុម្ភៈ ២០១៧ ភ្នំពេញ

**កិច្ចពិភាក្សាតាមទូរទស្សន៍ គូសបញ្ជាក់ពី ចក្ខុវិស័យឆ្នាំ២០១៧ សម្រាប់ប្រទេសកម្ពុជា។** លោកនាយកប្រតិបត្តិ និង បណ្ឌិត Leonie Lethbridge អគ្គនាយកធនាគារ ANZ រ៉ូយ៉ាល់ បានចូលរួមក្នុងការពិភាក្សាស្តីពី "កម្ពុជា និងខ្សែសង្វាក់បង្កើតតម្លៃសកល" ដែលរៀបចំដោយ បណ្ឌិត សុខ ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលនៃ

តទៅទំព័រ ២១

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី២១ លេខ១ ខែមីនា ឆ្នាំ២០១៧

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
+៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសម្រួលៈ យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្មៈ អ៊ុំ ចាន់ថា

សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៧ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh